# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅអនុវិទ្យាល័យ បឋមភូមិក្នុងខេត្តបាត់ដំបង

# The Implementation of School-Based Management at Lower Secondary School in Battambang Province


ដោយ/ by

**ងួន ផល្លី**

NGOUN PHALLY


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**


**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation ( CIESF )

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

## ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅអនុវិទ្យាល័យ

## បឋមភូមិក្នុងខេត្តបាត់ដំបង

## The Implementation of School-Based Management at Lower Secondary School in Battambang Province

ដោយ/ by

ងួន ផល្លី

NGOUN PHALLY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧-២០១៩

សាស្ត្រាចារ្យដឹកនាំ ៖ បណ្ឌិត សៀង សុវណ្ណា

សាស្ត្រាចារ្យដឹកនាំរង៖ លោក សៀង វាសនា

ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៩៦២៩ អយក.

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈួក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

នាងខ្ញុំសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា ″ **ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តបាត់ដំបង** ″ សម្រាប់បំពេញលក្ខខណ្ឌ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ (NIE) គឺជាស្នាដៃពិតប្រាកដរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់មាននរណាម្នាក់ បានសិក្សាស្រាវជ្រាវនិងប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំនេះ ឬនៅសាកលវិទ្យាល័យណាមួយ ឬវិទ្យាស្ថានថ្នាក់ស្មើ ឬខ្ពស់ជាងណាមួយឡើយ។ នាងខ្ញុំសូមបញ្ជាក់ជូនផងដែរថា ពុំមានសេចក្តីដកស្រង់ ឬ ខ្លឹមសារត្រង់ណាមួយ ឬ ការចុះបញ្ជីឯកសារយោងណាមួយដែលត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធឡើយ។

នាងខ្ញុំសូមអះអាងថានិក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាស្នាដៃចងក្រងរបស់នាងខ្ញុំពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ ធ្នូ ឆ្នាំ២០១៩

ហត្ថលេខាបេក្ខជន

**ខួន ផល្លី**

# លិខិតបញ្ជាក់

ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** ជាសាស្ត្រាចារ្យដឹកនាំ

លោក**សៀង វាសនា** ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

**លោកស្រី ង៉ូន ផល្លី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តបាត់ដំបង**» ពិតប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

.......................................... ..........................................

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** **លោក សៀង វាសនា**
នាយកវិទ្យាស្ថានជាតិអប់រំ គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (CIESF) Cambodia International Education Support Foundation ដែលបានរៀបចំ និងផ្តល់អាហារូបករណ៍ដល់នាងខ្ញុំបានសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំរយៈពេល២ឆ្នាំកន្លងមក។

នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងខ្លាំងបំផុតចំពោះគណៈកម្មការគ្រប់គ្រង និងដឹកនាំការបណ្តុះបណ្តាលវគ្គសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំគ្រប់លំដាប់ថ្នាក់ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃផ្ទេរនូវចំណេះដឹង បំណិន ឥរិយាបថ បទពិសោធន៍ល្អៗជាច្រើន ពិសេសលើផ្នែកគ្រប់គ្រងក្នុងវិស័យអប់រំដល់ពួកខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយហត់ឡើយ។ជាពិសេស នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងអនេកជូនចំពោះ លោកសាស្ត្រាចារ្យ **បណ្ឌិត សៀង សុវណ្ណា** ជាសាស្ត្រាចារ្យណែនាំ និង **លោក សៀង វាសនា** ជាសាស្ត្រាចារ្យជំនួយ ដែលលោកទាំងពីរតែងតែចំណាយពេលវេលាដ៏មមាញឹកពន្យល់ណែនាំ កែលម្អនូវចំណុចខ្វះខាត និងផ្តល់គន្លឹះល្អៗពីដំណាក់កាលមួយទៅដំណាក់កាលមួយ ទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់នាងខ្ញុំបានសម្រេចជោគជ័យ ។មួយចំណែកទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះ មិត្តភក្តិរួមជំនាន់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំទាំងអស់ដែលមានទឹកចិត្តល្អ ក្នុងការចែករំលែកនូវចំណេះដឹង បទពិសោធន៍ល្អៗព្រមទាំងចេះជួយលើកទឹកចិត្តគ្នាទៅវិញទៅមកទៀតផង ។ នាងខ្ញុំសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រងមន្ទីរអប់រំខេត្ត គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូនៃសាលាគោលដៅទាំងអស់ក្នុងខេត្តបាត់ដំបង ដែលបានសហការនិងសម្របសម្រួល យ៉ាងល្អប្រសើរក្នុងដំណើរការចុះប្រមូលទិន្នន័យ ដែលជាកត្តារួមចំណែកមួយយ៉ាងធំធេងក្នុងការធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់នាងខ្ញុំទទួលបានជោគជ័យ។

ជាទីបញ្ចប់នាងខ្ញុំសូមប្រសិទ្ធពរជ័យ ជូនចំពោះ ឯកឧត្តម លោក លោកស្រី ទាំងអស់សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន ប្រាជ្ញាឈ្លាសវៃប្រកបការងារអ្វីបានសម្រេចជោគជ័យ និងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ ៖ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

ប្រទេសកម្ពុជា ក៏ដូចជាប្រទេសជាច្រើននៅក្នុងពិភពលោកបាននិងកំពុងតែអនុវត្តការគ្រប់គ្រងតាមសាលារៀនតាមរយៈការធ្វើវិមជ្ឈការនៃការអប់រំ ។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណង ៖ ១-ស្វែងយល់អំពីកម្រិតនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តបាត់ដំបង និង ២-រកឱ្យឃើញអំពីបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រងតាមសាលារៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តបាត់ដំបង ។ ការស្រាវជ្រាវនេះបានធ្វើឡើងនៅសាលាគោលដៅ ០៤ដែលបាន និងកំពុងអនុវត្តការការគ្រប់គ្រងតាមសាលារៀនក្នុងខេត្តបាត់ដំបង។ភាគសំណាកក្នុងការស្រាវជ្រាវនេះមាន៖ គ្រូបង្រៀន ៥០នាក់ និងនាយកសាលា ៤នាក់។វិធីសាស្ត្រប្រមូលទិន្នន័យគឺបានមកពីកម្រងសំណួរបំពេញសម្រាប់គ្រូបង្រៀននិងកម្រងសំណួរសម្ភាសន៍សម្រាប់នាយកសាលា។

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា៖កម្រិតនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនមានកម្រិតល្អបង្គួរ។ លោកនាយកសាលាគោលដៅទាំង៤មានចំណុចជាច្រើនដែលត្រូវតាមស្តង់ដារបស់នាយកសាលាដូចជា ៖ កម្រិតវប្បធម៌និងបទពិសោធន៍ការងាររបស់លោកនាយក,តម្លាភាពក្នុងការគ្រប់គ្រង,ការកៀរគរថវិកា,ការវាយតម្លៃគ្រូ សិស្ស សាលារៀនច្បាស់លាស់,ការលើកទឹកចិត្តនិងដាក់ពិន័យរដ្ឋបាល ,ការចុះអធិការកិច្ចជាប្រចាំ និងការរក្សាទុកថវិកា ។ ចំណែកគ្រូបង្រៀនក៏រៀបចំកិច្ចតែងការបានល្អ,ប្រជុំបច្ចេកទេសបានទៀងទាត់,ការដាក់កិច្ចការផ្ទះបានល្អ, គ្រូជួបពិភាក្សាជាមួយមាតាបិតាសិស្សរៀនយឺតជាប្រចាំ។

ការអនុវត្តការគ្រប់គ្រងតាមសាលារៀនជួបនូវបញ្ហាមួយចំនួនដូចជា៖

១.)លទ្ធផលសិក្សារបស់សិស្សមួយចំនួននៅខ្សោយដែលនាំឱ្យអត្រាសិស្សបោះបង់ការសិក្សាខ្ពស់, ២.) ខ្វះគ្រូមុខវិជ្ជាគោល,៣.)សមត្ថភាពធនធាននៅមានកម្រិត,៤.)ខ្វះបន្ទប់សិក្សា និង សម្ភារៈសិក្សា, ៥.) ចំណែកការបំប៉នសិស្សរៀនយឺតមិនសូវបានម៉ត់ចត់ទេ។ទាំងនេះជាបញ្ហាសំខាន់ដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តការងារនេះ ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើការស្រាវជ្រាវបានផ្តល់អនុសាសន៍មួយចំនួន៖១.)សុំក្រសួងអប់រំ យុវជន និងកីឡាបន្តបើកវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពដល់លោកគ្រូ/អ្នកគ្រូ។២.)ស្នើឱ្យក្រសួងអប់រំសហការជាមួយមន្ទីរអប់រំដើម្បីប្រជុំផ្សព្វផ្សាយនិងណែនាំពីសារសំខាន់ឱ្យបានច្បាស់លាស់អំពីគម្រោងពង្រឹងការអប់រំមធ្យមសិក្សា (SEIP) ដល់លោកគ្រូ/អ្នកគ្រូ សហគមន៍ និងអាណាព្យាបាលសិស្ស ដើម្បីឱ្យពួកគាត់ជួយជំរុញលទ្ធផលសិក្សាសិស្សឱ្យកាន់តែប្រសើរឡើង។ ៣.)សូមឱ្យមន្ទីអប់រំ យុវជន និងកីឡាខេត្តបាត់ដំបងសហការជាមួយក្រសួងអប់រំក្នុងការចែងគោលការណ៍ផ្តល់គ្រូឱ្យបានច្បាស់លាស់តាមតម្រូវការជាក់ស្តែង និងឱ្យត្រូវតាមឯកទេសផង។ ៤.) សូមឱ្យគណៈគ្រប់គ្រងសាលារៀនពង្រឹងទំនាក់ទំនងល្អជាមួយ ៖ មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ អាជ្ញាធរដែនដី សម្បុរសជន សហគមន៍ អាណាព្យាបាលសិស្សនិងសិស្សានុសិស្ស ដើម្បីកៀរគរថវិកាសម្រាប់អភិវឌ្ឍសាលារៀន។

## Abstract

Cambodia, as well as many countries around the world have been implementing the School-Based Management (SBM) through the decentralization of education. This research aims to: 1.study the level of implementation of School Based Management at Lower Secondary Schools and 2.) identify the challenges in implementing SBM in Lower Secondary Schools.This research was conducted at four target schools in Battambang Province.The sample for the study included 50 teachers and 4 principals.The dada for this study was collected using structured questionnaires for teachers and the interview questionnaires for principals.

The result of the findings indicated that the level of implementing of School-Based Management was quite good.The four principals have almost completed the principals' standards. These good points include: their qualifications and experiences, their transparency in management, fund raising, teacher evaluation, students´ assessment, school effectiveness, motivation and Punishment, regular inspection and budget management. Teachers also prepare lesson plans well, they have regular technical meetings, give regular homework, and meet with parents and students regularly. However, there were some challanges found in implementing School Baaed-Management : 1.) poor students´ learning outcomes resulting in high dropout rates, 2) Lack of teachers, 3.) skill shortage of human resources , 4.) Lack of classroom and study materials , 5 .) The program to help slow learners is not practical.

In response to the challenges above, the study made the following recommendations: 1.) the Ministry of Education, Youth and Sports should provide more trainings for teachers. 2) the Ministry of Education Youth and Sports should cooperate with the Department of Education Youth and Sports in conducting the orientation of the program (SEIP) to provide more details to community /school teachers and parents to promote the students´achievements.3.)the Department of Education, Youth and Sports should work with the Ministry of Education to provide teachers as required with the right specialized teachers . 4) School principles should strengthen their relationship with: Education Officers at all levels, local authorities, donors, communities, parents and students to raise fund for school development.

## មាតិកា

សេចក្តីប្រកាសរបស់បេក្ខជន .......... i
លិខិតបញ្ជាក់ .......... ii
សេចក្តីថ្លែងអំណរគុណ .......... iii
មូលន័យសង្ខេប .......... iv
ABSTRACT .......... v
មាតិកា .......... vi
បញ្ជីក្រាប .......... ix

## ជំពូកទី១

## សេចក្តីផ្តើម

១.១. លំនាំបញ្ហា .......... ២
១.២. ចំណោទបញ្ហា .......... ៤
១.៣. គោលបំណងនៃការស្រាវជ្រាវ .......... ៥
១.៤. សំណួរស្រាវជ្រាវ .......... ៦
១.៥. សារៈសំខាន់នៃការស្រាវជ្រាវ .......... ៦
១.៦. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ .......... ៧
១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .......... ៨

## ជំពូកទី២

## រំលឹកទ្រឹស្តី

២.១. និយមន័យពាក្យគន្លឹះ .......... ១០
២.២. ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងតាមសាលារៀននៅកម្ពុជា .......... ១១
២.២.១.កំណែទម្រង់ការងាររៀន-បង្រៀន .......... ១១

២.២.២.កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល................................................................ ១១

២.២.៣.កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ................................................................ ១១

២.២.៤.កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស ........................................................ ១២

**២.៣.បទពិសោធន៍នៃការគ្រប់គ្រងតាមសាលារៀននៅប្រទេសនានា** ................ ១៣

២.៣.១.ការស្រាវជ្រាវទាក់ទងនឹងការចូលរួមរបស់សហគមន៍ ....................................១៤

២.៣.២.ទស្សនៈរបស់នាយក និងគ្រូបង្រៀនលើការអនុវត្ត SBM ..............................១៤

២.៣.៣.ការស្រាវជ្រាវទាក់ទងនឹងការសម្រេចចិត្ត....................................................១៥

## ជំពូកទី៣

## វិធីសាស្ត្រស្រាវជ្រាវ

**៣.១. ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ**............................................................ ១៧

**៣.២. ទីតាំងនៃការស្រាវជ្រាវ**........................................................................ ១៧

**៣.៣. ការជ្រើសរើសសំណាក** .......................................................................... ១៧

**៣.៤. ឧបករណ៍ស្រាវជ្រាវ** ............................................................................. ១៨

**៣.៥. ដំណាក់កាលនៃការប្រមូលទិន្នន័យ**......................................................... ១៩

**៣.៦. ការវិភាគទិន្នន័យ**...............................................................................២០

**៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ**...............................................................២១

## ជំពូកទី៤

## លទ្ធផល និងការពិភាក្សា

**៤.១.ការគ្រប់គ្រងរដ្ឋបាល** ........................................................................... ២៣

៤.១.១.ការបង្ហាញតម្លាភាពរបស់នាយកសាលា.........................................................២៣

៤.១.២. ការចូលរួមរបស់គ្រូបង្រៀនក្នុងការរៀបចំផែនការផ្សេងៗ...............................២៤

៤.១.៣. និតិវិធីរបស់នាយកក្នុងការកៀរគរថវិកា....................................................២៥

៤.១.៤. ការប្រមូលព័ត៌មានពីការវាយតម្លៃគ្រូ សិស្ស និង សាលារៀន........................២៦

៤.១.៥. ការលើកទឹកចិត្តគ្រូបង្រៀនដែលសកម្ម........................................................២៧

៤.១.៦. វិធានការរដ្ឋបាលចំពោះគ្រូដែលអសកម្ម.......................................................២៨

**៤.២. ការគ្រប់គ្រងការរៀន និងបង្រៀន**..............................................................២៩

៤.២.១. ការរៀបចំកិច្ចតែងការបង្រៀន.......................................................................២៩

៤.២.២. ការដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ.......................................................................៣០

៤.២.៣.ការប្រជុំបច្ចេកទេស.........................................................................................៣១

៤.២.៤. ការប្រឹក្សាយោបល់ជាមួយមាតាបិតាសិស្សរៀនយឺត..................................៣២

៤.២.៥. ចំនួនបន្ទប់សិក្សារបស់សិស្ស...........................................................................៣៣

**៤.៣. ការគ្រប់គ្រងធនធានមនុស្ស** .........................................................................៣៤

៤.៣.១ ចំនួនគ្រូបង្រៀនមុខវិជ្ជាគោល........................................................................៣៤

៤.៣.២. ការបំប៉ន និងការអភិវឌ្ឍសមត្ថភាពគ្រូ.........................................................៣៥

៤.៣.៣. ការចុះអធិការកិច្ច.............................................................................................៣៦

**៤.៤. ការគ្រប់គ្រងហិរញ្ញវត្ថុ**.......................................................................................៣៧

៤.៤.១. ការទុកដាក់ និងប្រើប្រាស់ថវិកា.....................................................................៣៧

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងសំណូមពរ

**៥.១. សេចក្តីសន្និដ្ឋាន**......................................................................................... ៤០

**៥.២. សំណូមពរ**.................................................................................................... ៤១

**៥.៣. ការស្រាវជ្រាវបន្ត**.......................................................................................... ៤២

**ឯកសារយោង** ................................................................................................ ៤៣

**ឧបសម្ព័ន្ធ** .....................................................................................................៤៧

# បញ្ជីក្រាប


ក្រាបទី១ ៖ការបង្ហាញតម្លាភាពរបស់នាយកោ..........................................................................២៣
ក្រាបទី២ ៖ ការចូលរួមរបស់គ្រូបង្រៀនក្នុងការរៀបចំផែនការផ្សេងៗ...................................២៤
ក្រាបទី៣ ៖ និតិវិធីរបស់នាយកក្នុងការប្រមូលមូលនិធិ ...........................................................២៥
ក្រាបទី៤ ៖ ការប្រមូលព័ត៌មានពីការវាយតម្លៃគ្រូ សិស្ស និង សាលារៀន ..............................២៦
ក្រាបទី៥ ៖ ការលើកទឹកចិត្តគ្រូដែលសកម្ម ..............................................................................២៧
ក្រាបទី៦ ៖ ការចេញវិធានការរដ្ឋបាលដល់គ្រូដែលអសកម្ម .....................................................២៨
ក្រាបទី៧ ៖ការរៀបចំកិច្ចតែងការបង្រៀន ..................................................................................២៩
ក្រាបទី៨ ៖ការដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ ..................................................................................៣០
ក្រាបទី៩ ៖ការប្រជុំបច្ចេកទេស ....................................................................................................៣១
ក្រាបទី១០៖ការប្រឹក្សាយោបល់ជាមួយមាតាបិតាសិស្សរៀនយឺត ...............................................៣២
ក្រាបទី១១៖ចំនួនបន្ទប់សិក្សាសម្រាប់សិស្ស ................................................................................ ៣៣
ក្រាបទី១២៖ ចំនួនគ្រូបង្រៀនមុខវិជ្ជាគោល ................................................................................. ៣៤
ក្រាបទី១៣៖ ការបំប៉ន និងការអភិវឌ្ឍសមត្ថភាពគ្រូ ...................................................................... ៣៥
ក្រាបទី១៤៖ការចុះអធិការកិច្ច ....................................................................................................... ៣៦
ក្រាបទី១៥៖ ការទុកដាក់ និងប្រើប្រាស់ថវិកា ............................................................................៣៧

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១- លំនាំបញ្ហា

រាជរដ្ឋាភិបាលនៃប្រទេសនានាជុំវិញពិភពលោកកំពុងតែស្វែងរកយុទ្ធសាស្ត្រជាច្រើន ដើម្បីឱ្យសេវាអប់រំកាន់តែមានគុណភាព និងធ្វើឱ្យអត្រានៃការចុះឈ្មោះចូលរៀនកើនឡើង ។ យុទ្ធសាស្ត្រមួយក្នុងចំណោមនោះ គឺការផ្តល់វិមជ្ឈការនៃការអប់រំទៅដល់សាលារៀន ក្នុងការសម្រេចចិត្តដោយបង្កើនការចូលរួមពីអាណាព្យាបាលសិស្ស និងសហគមន៍ក្នុងការងារសាលាដែលត្រូវបានគេស្គាល់ថាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល SBM (World bank,2007) ។ប្រទេសជាច្រើនក្នុងពិភពលោកបាននិងកំពុងអនុវត្តកំណែទម្រង់ SBM នេះ ដូចជា៖ ប្រទេសអូស្ត្រាលី កាណាដា អាមេរិក ប្រេស៊ីល អេស្បាញ ចក្រភពអង់គ្លេស និងនូវែលសេឡង់( World bank,2007) ។ ប្រទេសនៅអាស៊ីជាច្រើនទៀតក៏បានចាប់ផ្តើមអនុវត្ត SBM ជាបន្តបន្ទាប់ដែរ ដូចជាប្រទេសចិនហុងកុង(1991) ថៃ(1997) ឥណ្ឌូណេស៊ី(1999) និងហ្វីលីពីន (2001)។ប្រទេសកម្ពុជាក៏មិនខុសគ្នាពីប្រទេសទាំងអស់នោះដែរ ចាប់តាំងពីឆ្នាំ1998មកបាននិងកំពុងតែសិក្សាស្វែងយល់អំពីការគ្រប់គ្រងនៅតាមសាលារៀន តាមរយៈការអនុវត្តការធ្វើវិមជ្ឈការនៃការអប់រំ។ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានបំណងធ្វើឱ្យសាលារៀនក្លាយជាកន្លែងផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាប័ន្ន ប្រសិទ្ធភាព និងលើកកម្ពស់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ដូច្នេះហើយការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផលគឺជាយន្តការដ៏មានប្រសិទ្ធភាព ក្នុងការអនុវត្តវិមជ្ឈការនៃការអប់រំដើម្បីឱ្យការអប់រំទទួលបានគុណភាពខ្ពស់ ឆ្លើយតបទៅនឹងគោលដៅកំណត់( MoEYS , 2018 )។ យោងតាមឯកសារប្រវត្តិនៃការអប់រំ នៅប្រទេសកម្ពុជាតែងតែមានកំណែទម្រង់ និងការអភិវឌ្ឍវិស័យអប់រំជាបន្តបន្ទាប់។ បន្ទាប់ពីទទួលបានឯករាជ្យពីអាណានិគមបារាំងក្នុងឆ្នាំ១៩៥៤ ចំនួនសាលារៀនបឋមសិក្សាមានការកើនឡើងគួរឱ្យកត់សំគាល់ ក្នុងអំឡុងចុងទសវត្សឆ្នាំ១៩៥០ ហើយសាលាមធ្យមសិក្សាក៏មានការកើនឡើងផងដែរនៅ បំណាច់ចុងទសវត្សឆ្នាំ១៩៦០ (Blom & Nooijer, 1992)។ ប៉ុន្តែមកដល់សម័យប៉ុលពត ( 1975-1978 ) ប្រព័ន្ធអប់រំនៅកម្ពុជាត្រូវបានលុបបំបាត់ចោលទាំងស្រុង ហេដ្ឋារចនាសម្ព័ន្ធអប់រំត្រូវបានបំផ្លាញ ហើយគ្រូមួយចំនួនធំត្រូវបានគេសម្លាប់ (Dykstra & Kucita,1997)។ នៅដើមឆ្នាំ១៩៧៩ ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងប្រព័ន្ធអប់រំត្រូវបានកសាងឡើងវិញ(Blom & Nooijer, 1992)។ ចាប់តាំងពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ការអប់រំត្រូវ

បានគេចាត់ជាវិស័យដ៏សំខាន់បំផុតមួយ ដែលស្ថិតក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រទេសកម្ពុជា។គោលនយោបាយអប់រំជាច្រើនត្រូវបានបង្កើតឡើងដូចជាផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ២០០១-២០០៥ (the Ministry of Education, Youth and Sport [MoEYS], 2000), បានធ្វើបច្ចុប្បន្នភាព ESP ២០០៦-២០១០(MoEYS 2005) ដើម្បីសម្រេចបានគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា។ក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់អាទិភាពដល់ "ការអប់រំសម្រាប់ទាំងអស់គ្នា ការធ្វើឱ្យប្រសើរឡើងនៃការទទួលបានការអប់រំ ទាំងគុណភាព ការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាពសម្រាប់វិមជ្ឈការ"តាមរយៈកម្មវិធី ESP នេះ(Ministry of Education, Youth, and sport, 2001a, ទំ 1-3)។

ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងព្យាយាមអស់រយៈពេលជាច្រើនឆ្នាំក្នុងគោលបំណងដើម្បីឈានទៅអនុវត្ត SBM តាមរយៈការអនុវត្តគោលនយោបាយវិមជ្ឈការនៅក្នុងការអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡាបានប្តេជ្ញាចិត្តបន្តអនុវត្តគោលនយោបាយវិមជ្ឈការអប់រំដោយបញ្ជាក់ថា" អាទិភាពគោលនយោបាយដែលកំពុងបន្តរបស់ក្រសួងគឺដើម្បីអនុញ្ញាតឱ្យមានប្រតិភូអំណាចនិងការទទួលខុសត្រូវកាន់តែច្រើនឡើងដល់ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងសាលារៀន។ នាយកដ្ឋាននានាក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងអនុវត្តកាន់តែខ្លាំងឡើងៗនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យអប់រំ ព្រមទាំងការត្រួតពិនិត្យការអនុវត្តកម្មវិធី (MoEYS, ២០០៥ ទំ ១៥) ដើម្បីឆ្ពោះទៅរកការគ្រប់គ្រងសាលារៀនតាមរយៈការអនុវត្តវិមជ្ឈការអប់រំនៅក្នុងកម្មវិធីមួយចំនួន ។ កម្មវិធីមួយក្នុងចំណោមកម្មវិធីទាំងនោះត្រូវបានគេស្គាល់ថាជាកម្មវិធីសកម្មភាពអាទិភាព (PAP) ដែលផ្តោតលើ ២៤ រាជធានី-ខេត្តទូទាំងប្រទេសហើយត្រូវបានចាប់អនុវត្តនៅក្នុងឆ្នាំ ២០០០ ( MoEYS, ២០០១b) ។ គោលបំណងនៃកម្មវិធីនេះគឺដើម្បីផ្តល់ការអប់រំសម្រាប់សេវាកម្មដល់កុមារកម្ពុជាទាំងអស់ (MoEYS,២០០១) និងកាត់បន្ថយបន្ទុកចំណាយលើគ្រួសារក្រីក្របំផុត ។ PAP បានចូលរួមចំណែកក្នុងការលើកកម្ពស់វិមជ្ឈការនៃសេវាកម្មគ្រប់គ្រងការអប់រំ តាមរយៈមជ្ឈមណ្ឌលគ្រប់គ្រងថវិកាតាមមូលដ្ឋាននិងតាមស្ថាប័ន"( ធនាគារអភិវឌ្ឍន៍អាស៊ី,២០០២,ទំ២ ) ។ កម្មវិធីមួយទៀតបានសិក្សាពី SBMតាមរយៈការចូលរួមរបស់សហគមន៍ក្នុងការអប់រំនៅកម្ពុជាគឺការអនុវត្តសាលារៀនកម្រង នៅសាលាបឋមសិក្សា។ កម្រងគឺជាក្រុមសាលារៀននៅក្នុងតំបន់មួយដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវបណ្តាញគាំទ្រគ្នាទៅវិញទៅមក នេះបើយោងតាមគោលការណ៍ណែនាំដែលបានបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។ វិមជ្ឈការនៃសេវាអប់រំ ត្រូវបានគេសន្មតថាដើម្បីកៀរគរធនធានក្នុងស្រុក និងការចូលរួមរបស់

សហគមន៍។ គណៈកម្មាធិការទ្រទ្រង់សាលារៀនក្នុងតំបន់ (LSSC) ត្រូវបានប្រកាសដោយក្រសួងអប់រំ យុវជន និងកីឡានៅឆ្នាំ ១៩៩៤ ហើយត្រូវបានជ្រើសរើសនៅក្នុងសហគមន៍សាលារៀន។ សមាជិកនៃ LSSC មាននាយកសាលាជាប្រធាន អាជ្ញាធរមូលដ្ឋាន(មេភូមិ / មេឃុំ) ជាអនុប្រធាន តំណាងគ្រូបង្រៀន តំណាងសហគមន៍ តំណាងមាតាបិតា និងតំណាងសិស្ស/និស្សិតជាសមាជិក (ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០០៩) ) ។ ផ្អែកលើតម្រូវការក្នុងស្រុក មុខងាររបស់ LSSC បានរួមបញ្ចូលទាំងការថែរក្សាគុណភាពក្នុងការអប់រំ ដូចជាការត្រួតពិនិត្យថវិកាប្រតិបត្តិសាលារៀន (PAP) និងការធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីការរៀបចំផែនការអភិវឌ្ឍសាលារៀននិងសកម្មភាពសិក្សារបស់សាលា។ គណៈកម្មការទាំងនេះមានគោលបំណងដើម្បីកែលម្អការគ្រប់គ្រងនិងការចូលរួមរបស់សាលា។ ទោះយ៉ាងណារចនាសម្ព័ន្ធអង្គភាពប្រហែលជាមានតែលើក្រដាស (Pellini, ២០០៧) ហើយនៅក្នុងបរិបទជាក់ស្តែងគឺកង្វះការចូលរួមពី LSSCs ត្រូវបានគេមើលឃើញយ៉ាងច្បាស់។ លទ្ធផលនេះមកពីស្រុក ភូមិនិងសាលារៀនមិនមានថវិកាចរន្តគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងការចំណាយ ដែលត្រូវការដោយទំនួលខុសត្រូវក្នុងការចែកចាយរបស់ពួកគេ។ មូលនិធិបែបនេះ ចាំបាច់ត្រូវទទួលបានពី "ថ្នាក់កំពូល" ពោលគឺក្រសួងអប់រំ យុវជន និងកីឡា។ ភូមិមិនមានប្រភពចំណូលទេ ហើយសាលារៀនខ្លះមានការចូលរួមចំណែកតិចតួចពីឪពុកម្តាយ ពីអ្នកភូមិ ហើយប្រាក់ដែលពួកគេទទួលបានតិចតួចអាចជាអង្ករសម្រាប់គ្រូ ឬ ជាកម្លាំងពលកម្មសម្រាប់ជួសជុលសាលារៀនប៉ុណ្ណោះ។

## ១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ

ការស្តារប្រព័ន្ធអប់រំនៅកម្ពុជានៅតែបន្តជួបបញ្ហាប្រឈមជាច្រើនដូចជា ៖ កង្វះខាតធនធានមនុស្ស វិធីសាស្ត្របង្រៀន និងធនធានថវិកា។ វិមជ្ឈការតម្រូវឱ្យមានរចនាសម្ព័ន្ធហិរញ្ញវត្ថុនិងការគ្រប់គ្រងល្អ និងក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់ត្រួតពិនិត្យនិងសវនកម្ម។ ជាទូទៅត្រូវបានគេទទួលស្គាល់ថាជំនាញគ្រប់គ្រងនៅមានការខ្វះខាត ជាពិសេសនិន្នាការបច្ចុប្បន្នឆ្ពោះទៅរកវិមជ្ឈការក្នុងវិស័យអប់រំនិងទំទួលខុសត្រូវក្នុងតំបន់កាន់តែច្រើនក្នុងការសម្រេចចិត្ត។

បទពិសោធន៍របស់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការអនុវត្តកម្មវិធីទាំងពីរ(កម្មវិធីសកម្មភាពអាទិភាព និងកម្មវិធីសាលាកម្រង) បង្ហាញថាប្រទេសកម្ពុជាបានបោះជំហានជាវិជ្ជមានមួយឆ្ពោះទៅរក SBM តាមរយៈការផ្តល់សិទ្ធិអំណាចដល់សាលារៀនដើម្បីរៀបចំ

ផែនការអភិវឌ្ឍន៍សាលារៀននិងថវិកាប្រចាំឆ្នាំទោះបីជាតួនាទីរបស់សមាជិកសហគមន៍មូលដ្ឋាននៅមានកម្រិតក្នុងការគ្រប់គ្រងសាលារៀនតាមមូលដ្ឋានក៏ដោយ។ ជាការពិតណាស់សព្វថ្ងៃមានបញ្ហាមួយចំនួន ដែលគេបានជួបប្រទះក្នុងការអនុវត្តកម្មវិធីទាំងពីររួមមាន ៖ តួនាទីមិនច្បាស់លាស់នៅគ្រប់កម្រិតទាំងអស់នៅក្នុងសាលាកម្រង។ ម៉្យាងវិញទៀតការពន្យាពេលនៃការទម្លាក់ថវិកាឬការចំណាយថវិកា កង្វះខាតគោលការណ៍ណែនាំច្បាស់លាស់ទាក់ទងនឹងតួនាទីនិងទំនួលខុសត្រូវសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ព្រមទាំងកង្វះជំនាញនៅថ្នាក់ក្រោមជាតិនិងនៅតាមសហគមន៍មូលដ្ឋាន (MoEYS, ២០០១d) ធ្វើឱ្យប្រសិទ្ធភាពនៃការអនុវត្ត PAP មានភាពយឺតយ៉ាវ ។

តាមរយៈបទពិសោធន៍នៃការអនុវត្តកម្មវិធីទាំងពីរនេះអាចសន្និដ្ឋានបានថាការអនុវត្តវិមជ្ឈការដោយមិនដឹងពីកត្តារាំងស្ទះនោះនឹងប៉ះពាល់ដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព។

បច្ចុប្បន្នគម្រោងពង្រឹងការអប់រំមធ្យមសិក្សា(SEIP)ដែលគាំទ្រថវិកាដោយធនាគារពិភពលោកបាននិងកំពុងអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅតាមបណ្តាសាលាមធ្យមសិក្សាបឋមភូមិ(ថ្នាក់ទី៧ដល់ទី៩)មួយចំនួនក្នុងរាជធានីខេត្ត ទូទាំងប្រទេស (World Bank ,2017)។ ដោយឡែកសម្រាប់ខេត្តបាត់ដំបងក៏មានសាលារៀន ចំនួន៤ ដែលកំពុងអនុវត្តកម្មវិធីនេះ។ ដូច្នេះហើយទើបនាំឱ្យមានការសិក្សាស្រាវជ្រាវ អំពីកម្រិតនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន(SBM) ព្រមទាំងបញ្ហាប្រឈមសំខាន់ៗដែលរាំងស្ទះដល់ការអនុវត្ត SBM នៅតាមសាលាមធ្យមសិក្សាបឋមភូមិនៅខេត្តបាត់ដំបង។

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណង ៖

១. សិក្សាអំពីកម្រិតនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមធ្យមសិក្សាបឋមភូមិនៅក្នុងខេត្តបាត់ដំបង។

២.សិក្សាពីបញ្ហាប្រឈមក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមធ្យមសិក្សាបឋមភូមិនៅក្នុងខេត្តបាត់ដំបង។

## ១.៤- សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវខាងលើ អ្នកសិក្សាស្រាវជ្រាវបានកំណត់លើកយកសំណួរស្រាវជ្រាវចំនួនពីរមកពិភាក្សាដូចខាងក្រោម៖

១-តើការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមធ្យមសិក្សាបឋមភូមិនៅក្នុងខេត្តបាត់ដំបងមានកម្រិតដូចម្ដេច?

២-តើមានបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមធ្យមសិក្សាបឋមភូមិនៅក្នុងខេត្តបាត់ដំបង?

## ១.៥- សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបង្ហាញពីសារៈសំខាន់ដូចតទៅ៖

### ចំពោះសាលារៀន

- ជួយឱ្យអ្នកពាក់ព័ន្ធក្នុងអង្គភាពស្វែងយល់អំពីកម្រិតនៃការអនុវត្តគម្រោងនេះព្រមទាំងដកស្រង់យកនូវបទពិសោធន៍ល្អៗមកអនុវត្ត និងចៀសវាងនូវបញ្ហាប្រឈមនានាដែលរាំងស្ទះដល់ការអនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល។
- ស្វែងរកដំណោះស្រាយទាន់ពេលវេលាដើម្បីជំរុញការអនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលឱ្យកាន់តែមានប្រសិទ្ធភាពឆ្លើយតបទៅនឹងគោលដៅកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។

### ចំពោះក្រសួងអប់រំ

- យល់អំពីការអនុវត្ត និងបញ្ហាប្រឈមជាក់ស្តែងក្នុងការអនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលនៅសាលាមធ្យមសិក្សាបឋមភូមិ ដើម្បីស្វែងរកយុទ្ធសាស្ត្រផ្សេងៗក្នុងការជួយដល់ការងារគ្រប់គ្រងនេះឱ្យកាន់តែមានប្រសិទ្ធភាព។

### ចំពោះអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ

- ទុកជាឯកសារសម្រាប់ជាជំនួយដល់ការស្រាវជ្រាវបន្តបន្ទាប់ទៀត។

## ១.៦- ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ទិន្នន័យនៃការស្រាវជ្រាវនេះ ប្រមូលតែពីសាលាចំនួន៤ដែលកំពុងអនុវត្តការគ្រប់គ្រងតាមសាលារៀននៅក្នុងស្រុកចំនួន០៤ និងធ្វើតែនៅក្នុងខេត្តបាត់ដំបងប៉ុណ្ណោះ ។ សាលាចំនួន៤នេះ អាចមិនមែនជាតំណាងឱ្យសាលាទាំងអស់នៅក្នុងខេត្តបាត់ដំបងនោះទេ ខ្លឹមសារប្រធានបទផ្តោតលើកម្រិតនៃការគ្រប់គ្រងសាលារៀន៤ចំណុច ៖ ការគ្រប់គ្រងរដ្ឋបាល,ការគ្រប់គ្រងការរៀន-បង្រៀន,ការគ្រប់គ្រងបុគ្គលិក និងការគ្រប់គ្រងហិរញ្ញវត្ថុ។ ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះមានគុណប្រយោជន៍ អាចជឿទុកចិត្តបាន និងស៊ីជម្រៅគ្រប់ជ្រុងជ្រោយ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកលោកនាយក ឬលោកស្រីនាយិកា គ្រូបង្រៀនមុខវិជ្ជាគោលទាំង៦ នៅកម្រិតមធ្យមសិក្សាបឋមភូមិ ថ្នាក់ទី៧ ទី៨ និងទី៩ មកធ្វើជាសំណាកក្នុងការសិក្សាស្រាវជ្រាវនេះដូច្នេះលទ្ធផលនៃការស្រាវជ្រាវនេះអាចមិនតំណាងឱ្យទូទាំងខេត្ត។ ម្យ៉ាងវិញទៀតក្នុងការស្រាវជ្រាវនេះអ្នកស្រាវជ្រាវបានធ្វើបទសម្ភាសន៍លោកនាយក ឬ លោកស្រីនាយិកាចំនួនតែ ០៤ នាក់ ចំណែកលោកគ្រូ អ្នកគ្រូចំនួនតែ ៥០នាក់ ត្រូវបានជ្រើសរើសដើម្បីឱ្យបំពេញកម្រងសំណួរ ដាច់ដោយឡែកពីគ្នា ដែលរៀបចំឡើងដោយអ្នកសិក្សាស្រាវជ្រាវក៏អាចមិនមែនជាតំណាងនៅទូទាំងខេត្ត បើទោះបីអ្នកស្រាវជ្រាវព្យាយាមជ្រើសរើសសំណាកទាំងនោះធ្វើជាតំណាងក៏ដោយ។

## ១.៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា ៥ ជំពូកធំៗ៖

ជំពូកទី១៖ *សេចក្តីផ្តើម* នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការសិក្សាស្រាវជ្រាវ សំណួរស្រាវជ្រាវ ព្រមទាំងដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវលើប្រធានបទ "**ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តបាត់ដំបង**"។

ជំពូកទី២៖ *រំលឹកទ្រឹស្តី* នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកនូវទ្រឹស្តីចាស់ៗពាក់ព័ន្ធនឹងប្រធានបទ និងពីអ្នកសិក្សាស្រាវជ្រាវមុនៗតាមរយៈសៀវភៅ កម្រងអត្ថបទស្រាវជ្រាវជាតិនិងអន្តរជាតិ លិខិតបទដ្ឋានគតិយុត្ត សេចក្តីប្រកាស សារាចរណ៍ណែនាំ និងឯកសារពាក់ព័ន្ធនានារបស់ក្រសួងអប់រំ យុវជន និងកីឡានិងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើជាគំនិតនិងជាទុនសម្រាប់ការស្រាវជ្រាវ និងការបង្កើតជាស្នាដៃថ្មី។

***ជំពូកទី៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ*** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសសំណាក និងប្រភេទសំណាក ព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យ តាមរយៈកម្មវិធី SPSS និងកម្មវិធី Ms. Excel សម្រាប់សង់ក្រាហ្វិកនិងផ្តុំទិន្នន័យបញ្ចូលគ្នា។

***ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ*** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានយកទិន្នន័យដែលប្រមូលបានមកធ្វើការវិភាគនិងធ្វើការបកស្រាយឱ្យបានយ៉ាងក្បោះក្បាយដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវកែលម្អនៅក្នុងបរិបទជាក់ស្តែងនៃការគ្រប់គ្រងតាមសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តបាត់ដំបង។

***ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ***

ជាផ្នែកមួយដ៏សំខាន់ ដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការថ្លឹងថ្លែងមុននឹងធ្វើការសន្និដ្ឋានទៅលើចំណុចរួមទាំងអស់ដែលបានវិភាគ ព្រមទាំងផ្តល់ជាសំណូមពរ មួយចំនួនដល់ក្រសួងអប់រំ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អ្នកសិក្សាស្រាវជ្រាវក្រោយៗ និងភាគីពាក់ព័ន្ធក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍ និងធ្វើឱ្យស្ថានភាពនៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តបាត់ដំបងកាន់តែមានប្រសិទ្ធភាពជាងមុន។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១- និយមន័យពាក្យគន្លឹះ

តើការគ្រប់គ្រងតាមសាលារៀន ឬការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) មានអត្ថន័យដូចម្តេច?

ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល(SBM) គឺជាការធ្វើវិមជ្ឈការសិទ្ធិអំណាចពីថ្នាក់កណ្តាល ទៅថ្នាក់សាលារៀន (Caldwell, 2005) ។ ចំណែកឯលោក Wongs (2003,ទំព័រ 243) បានឱ្យនិយមន័យ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) ថាគឺជាការធ្វើវិមជ្ឈការនៃការសម្រេចចិត្តពីថ្នាក់នាយកដ្ឋានអប់រំទៅថ្នាក់សាលារៀន ទាក់ទងនិងនិតិវិធីគ្រប់គ្រងបុគ្គលិក ការធ្វើផែនការ និងគ្រប់គ្រងហិរញ្ញវត្ថុ និងបំណែងចែកកម្មវិធីសិក្សា។ បើតាមការលើកឡើងរបស់លោក Herman (1991,ទំព័រVi) ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) គឺជារចនាសម្ព័ន្ធនិងជាដំណើរការមួយដែលអនុញ្ញាតឱ្យមានការសម្រេចចិត្តកម្រិតសាលារៀន ដែលទាក់ទងនឹងការគ្រប់គ្រងមន្ត្រី ការគ្រប់គ្រងថវិកា គោលនយោបាយ និងបញ្ហាផ្សេងៗទៀតដែលពាក់ព័ន្ធនឹងអភិបាលកិច្ចមូលដ្ឋានសាលារៀន ហើយវាក៏ជាដំណើរការមួយដែលមានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងការសម្រេចចិត្តទាក់ទងនឹងការងារសាលារៀន នីមួយៗ។ តាមរយៈសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) គឺមានន័យថាការផ្តល់ស្វ័យភាពក្នុងការសម្រេចចិត្តទៅដល់ថ្នាក់កម្រិតមូលដ្ឋាន ដោយផ្អែកលើលទ្ធផលនៃការអនុវត្តការងាររបស់សាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។

**ចំណាំ** ៖ School Based Management (SBM) ត្រូវបានគេឱ្យឈ្មោះថាការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលសម្រាប់បឋមសិក្សា) ឬការគ្រប់គ្រងតាមសាលារៀន(សៀវភៅណែនាំប្រតិបត្តិស្តីការគ្រប់គ្រងតាមសាលារៀនសម្រាប់មធ្យមសិក្សា)។

## ២.២- ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងតាមសាលារៀននៅកម្ពុជា

សាលារៀន គឺជាអង្គភាពមួយដ៏សំខាន់ក្នុងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់មូលដ្ឋាន។ ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM) បានក្លាយជាប្រធានបទដ៏ពេញនិយមមួយ ក្នុងទសវត្សរ៍ចុងក្រោយនេះ។ការធ្វើវិមជ្ឈការមានលក្ខណៈជាប្រព័ន្ធផ្អែកលើស្វ័យភាពសាលារៀន សំដៅជំរុញការអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ សេចក្តីណែនាំ និងគោលការណ៍ឱ្យសម្រេចបានតាមចំណុចដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

ដើម្បីសម្រេចបានតាមផែនការនេះ ក្រសួងអប់រំ យុវជន និងកីឡាសហការជាមួយអង្គការសង្គ្រោះកុមារ បានរៀបចំចងក្រងឯកសារជំនួយស្មារតី នៃការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (SBM)នៅបឋមសិក្សាដោយផ្តោតលើចំណុចសំខាន់ៗចំនួន៤គឺ ៖ ១.ការគ្រប់គ្រងរដ្ឋបាលសាលារៀន,២.ការងាររៀន-បង្រៀន និងអនុវត្តកម្មវិធីសិក្សា, ៣.ការគ្រប់គ្រងធនធានមនុស្ស ( ការអភិវឌ្ឍសមត្ថភាពគ្រូ និងការងារអធិការកិច្ច ) និង ៤.ការគ្រប់គ្រងថវិកាសាលារៀន ( សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលសម្រាប់បឋមសិក្សា ឆ្នាំ២០១៧)។ នៅក្នុងបទបង្ហាញមួយរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានធ្វើឡើងក្នុងថ្ងៃទិវាគ្រូបង្រៀន ០៥តុលា ២០១៨ ក៏បានលើកយកកំណែទម្រង់ការគ្រប់គ្រងអប់រំ ទាំង៤ចំណុចខាងលើនេះមកជជែកវែកញែកនិងពិភាក្សាផងដែរ។ ចំណុចទាំងបួននោះរួមមាន៖

### ២.២.១.កំណែទម្រង់ការងាររៀន-បង្រៀន ៖

- ការកែលម្អវិធីសាស្ត្របង្រៀន និងការដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល។
- ការកែលម្អការរៀន និងបង្រៀនជាពិសេសគឺវិធីសាស្ត្របង្រៀន
- ការធ្វើវង្វាយតម្លៃសិស្សជាប្រចាំ (ការធ្វើតេស្ត)

### ២.២.២.កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល៖

- ការអនុវត្តគោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព
- ការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងសាលារៀន

### ២.២.៣.កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ

- ការបង្កើនការបែងចែកថវិកា ផ្សារភ្ជាប់នឹងគោលនយោបាយអប់រំ
- ការបង្កើនស្វ័យភាព និងគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀន
- ការធ្វើសវនកម្មថវិកាអប់រំទៀងទាត់

**២.២.៤.កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស** (ការអភិវឌ្ឍសមត្ថភាពគ្រូនិងការងារអធិការកិច្ច)

- កំណែទម្រង់ការបណ្ដុះបណ្ដាលគ្រូបង្រៀនពី១២បូក២ទៅ១២បូក៤
- ការធ្វើវិក្រិតការគ្រូដោយផ្ដោតលើវិធីសាស្រ្តបង្រៀន និងកម្មវិធីបំប៉ននៅនឹងកន្លែង។
- ការអនុវត្តការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ។

ដូច្នេះចំណុចទាំង៤ដែលបានលើកឡើងខាងលើនេះ គឺជាចំណុចអាទិភាពដែលជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងតាមសាលារៀន។

ដើម្បីជំរុញឱ្យការដឹកនាំ និងគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាពក្រសួងក៏បានបង្កើតស្តង់ដានាយកសាលាមធ្យមសិក្សា ដែលស្តង់ដានោះបញ្ជាក់ពីកម្រិតអប្បរមានូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលនាយកសាលាត្រូវមានមុនពេល និងក្នុងពេលបំពេញតួនាទីជានាយកសាលា។ ស្តង់ដាទាំងនោះរួមមាន៖

**ស្តង់ដាទី១**៖កម្រិតវប្បធម៌និងបទពិសោធន៍ការងារ
**ស្តង់ដាទី២**៖សមត្ថភាព និងគុណសម្បត្តិនាយកសាលារៀន
**ស្តង់ដាទី៣**៖បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍
**ស្តង់ដារទី៤**៖ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន
**ស្តង់ដាទី៥**៖ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងរៀន
**ស្តង់ដាទី៦**៖ការផ្សារភ្ជាប់សាលារៀននិងសហគមន៍

ក្រៅពីនោះក្រសួងក៏បានបង្កើតនូវស្តង់ដាសាលារៀនមធ្យមសិក្សាមានប្រសិទ្ធភាពផងដែរ។យោងតាមសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន សម្រាប់មធ្យមសិក្សា សាលារៀនដែលអនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ត្រូវតែជាសាលារៀនដែលមានស្តង់ដាសាលារៀនមធ្យមសិក្សាមានប្រសិទ្ធភាព ៩ចំណុចគឺ៖

- ទី១៖ វត្ថុបំណងគោលនយោបាយសាលារៀន
- ទី២៖ ការបង្រៀន និងរៀន
- ទី៣៖ មាតាបិតា និងសហគមន៍ជួយដល់ការសិក្សាសិស្ស
- ទី៤៖សិស្ស និងសេវាជួយសិស្ស
- ទី៥៖ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន

- ទី៦៖ ធនធានមនុស្ស
- ទី៧៖ សៀវភៅសិក្សាគោល និងសម្ភារៈបង្រៀន និងរៀន
- ទី៨៖ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន
- ទី៩៖ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ

## ២.៣- បទពិសោធន៍នៃការគ្រប់គ្រងតាមសាលារៀននៅប្រទេសនានា

តាមរយៈការស្រាវជ្រាវឯកសារផ្សេងៗដែលបានសិក្សាទៅលើសាលារៀននានាដែលទទួលជោគជ័យ បានបង្ហាញឱ្យឃើញថាលក្ខណៈវិនិច្ឆ័យនៃសាលាដែលជោគជ័យគឺមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ និងពីបរិបទមួយទៅបរិបទមួយទៀត។ មានកត្តាឬលក្ខខណ្ឌជាច្រើនដែលនាំឱ្យសាលារៀនទទួលបានភាពជោគជ័យ ហើយយុទ្ធសាស្ត្រផ្សេងៗជាច្រើនក៏ត្រូវបានយកមកប្រើប្រាស់ដើម្បីឱ្យសាលាកាន់តែរីកចម្រើនផងដែរ ។ កត្តាឬលក្ខខណ្ឌទាំងនោះមាន៤គឺ ៖ សម្ភារៈបរិក្ខាសាលា,នាយកសាលា, គ្រូបង្រៀន,និង សិស្ស។

១.សម្ភារៈបរិក្ខាសាលារៀន៖ កត្តាចាំបាច់ដែលធ្វើឱ្យសាលារៀនទទួលបានជោគជ័យគឺសាលាត្រូវមានសម្ភារៈបរិក្ខាគ្រប់គ្រាន់ដូចជាសម្ភារៈសម្រាប់បង្រៀន និងរៀន,បន្ទប់ពិសោធន៍,បណ្ណាល័យ,និងសម្ភារៈចាំបាច់ផ្សេងទៀត។

២.នាយកសាលា ៖ ករណីសិក្សាជាច្រើនបានបង្ហាញថា សាលាដែលជោគជ័យ គឺជាសាលាដែលនាយកមានបទពិសោធន៍ច្រើន។ នាយកដែលធ្វើការច្រើនឆ្នាំ និងបានទទួលការបណ្តុះបណ្តាល ច្រើនមានចំណេះដឹងទូលំទូលាយ មានភាពជឿជាក់ ព្រមទាំងស្រឡាញ់ចូលចិត្តខ្លាំងក្នុងការអនុវត្ត និងរៀនសូត្រពីទ្រឹស្តីនៃការគ្រប់គ្រង។

៣.គ្រូបង្រៀន៖ គ្រូបង្រៀននៅសាលារៀនដែលជោគជ័យគឺគ្រូបង្រៀនដែលមានគុណវុឌ្ឍ។គ្រូបង្រៀនភាគច្រើនត្រូវបានគេបណ្តុះបណ្តាលដើម្បីអភិវឌ្ឍវិធីសាស្ត្រដែលជះឥទ្ធិពលដល់គុណភាព និងលទ្ធផលនៃការសិក្សារបស់សិស្ស។

៤.សិស្ស៖ តាមរយៈការស្រាវជ្រាវបានឱ្យដឹងថាសាលារៀនអាចជោគជ័យអាស្រ័យលើការលើកទឹកចិត្តតាមរយៈសមិទ្ធផល និងការគោរពខ្លួនឯងនិងការស្រឡាញ់ចូលចិត្តសាលារៀនរបស់សិស្ស។

### ២.៣.១.ការស្រាវជ្រាវទាក់ទងនឹងការចូលរួមរបស់សហគមន៍

ការស្រាវជ្រាវមួយធ្វើឡើងដោយ Shoraku នៅសាលាបឋមសិក្សា៣កន្លែងនៅស្រុកកោះធំ, ខេត្តកណ្ដាលប្រទេសកម្ពុជា បានរកឃើញថា៖ អ្នកពាក់ព័ន្ធភាគច្រើនពុំសូវចូលរួមក្នុងការងារសាលារៀនទេ។ មានតែសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស)តិចតួចប៉ុណ្ណោះដែលបានចូលរួមបំពេញតួនាទីក្នុងការជួយដល់ការងារគ្រប់គ្រងសាលារៀន។

ចំណែកការស្រាវជ្រាវមួយទៀតដែលធ្វើឡើងនៅសាលាបឋមសិក្សា ៣កន្លែង នៅប្រទេសកម្ពុជាទាក់ទងនឹងការចូលរួមរបស់សហគមន៍បានរកឃើញថាគ្មានអាណាព្យាបាលសិស្សណាម្នាក់បានចូលរួមជាមួយគ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន ក្នុងការរៀបចំផែនការអភិវឌ្ឍសាលារៀន សកម្មភាពផ្សេងៗ និងការពិភាក្សាអំពីការប្រើប្រាស់ថវិកាសាលារៀននោះទេ (Shoraku 2005,2007,2008a ,2008b)។

ក្នុងឆ្នាំ២០០២,ការស្រាវជ្រាវមួយបានធ្វើឡើងជាមួយសាលាបឋមសិក្សានិងមធ្យមសិក្សាចំនួន១៥០ដើម្បីសិក្សាស្វែងយល់អំពីបញ្ហានេះ។លទ្ធផលបានបង្ហាញថាមានការចូលរួមតិចតួចក្នុងក្រុមធ្វើការសម្រេចចិត្តនៅតាមសាលារៀន ហើយអ្នកស្រាវជ្រាវរកឃើញថាក្រុមការងារដែលធ្វើការសម្រេចចិត្តដោយខ្វះការចូលរួមពីតំណាងសហគមន៍គឺទំនងជាមិនសូវស្វែងរកជម្រើសច្រើនមុនពេលសម្រេចចិត្តនោះទេ ហើយក៏ងាយស្ថិតក្នុងស្ថានភាពដែលជាចំណាប់អារម្មណ៍តូចចង្អៀតរបស់បុគ្គលជាជាងគោលដៅក្រុមទាំងមូល(Walker,2002,p.17)។

ការខ្វះការចូលរួមពីសហគមន៍ ក៏ជាបញ្ហាប្រឈមមួយក្នុងការអនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលផងដែរ។ ដូចលោក Rogers និងលោក Chung (1993) បានលើកឡើងថាឧបសគ្គមួយក្នុងចំណោមឧបសគ្គជាច្រើន ដែលរាំងស្ទះក្នុងដំណើរការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល គឺការខ្វះការចូលរួមពីអាណាព្យាបាលសិស្សក្នុងកិច្ចការអភិបាលកិច្ចសាលារៀន។

### ២.៣.២.ទស្សនៈរបស់នាយក និងគ្រូបង្រៀនលើការអនុវត្ត SBM

យោងតាមការស្រាវជ្រាវមួយដែលបានធ្វើឡើងដោយJoyce,John & Joash(២០១៣) នៅសាលាមធ្យមសិក្សាក្នុងប្រទេស Kenya បានបង្ហាញថាការអនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលគឺនាំមកនូវផលវិជ្ជមានជាច្រើនសម្រាប់សាលារៀនដូចជាៈការធ្វើឱ្យប្រសើរឡើងនូវគុណនេយ្យភាព និងតម្លាភាពសាលារៀន,ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព,

ព្រមទាំងការអប់រំប្រកបដោយគុណភាព ។ ប៉ុន្តែមានបញ្ហាប្រឈមខ្លះៗក្នុងការអនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលនេះៈលទ្ធផលសិក្សាសិស្សមិនល្អ,អត្រាបោះបង់ការសិក្សាខ្ពស់,អត្រាសិស្សខ្ពស់,គ្រូមិនគ្រប់គ្រាន់។

ការអនុវត្តការគ្រប់គ្រងតាមសាលារៀននេះ (SBM) បានធ្វើឱ្យបន្ទុកការងារកាន់តែច្រើនដល់នាយកសាលាក៏ដូចជាគ្រូបង្រៀនផងដែរ ។ មិនតែប៉ុណ្ណោះការងារនេះទាមទារឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ទាំងការប្តេជ្ញាចិត្តមោះមុត ទាំងធនធាន ទាំងជំនាញ ទាំងការអត់ធ្មត់ និងការយល់អធ្យាស្រ័យគ្នារវាងដៃគូរសហការ (Joyce,John & Joash,២០១៣)។

## ២.៣.៣.ការស្រាវជ្រាវទាក់ទងនឹងការសម្រេចចិត្ត

ករណីសិក្សាមួយត្រូវបានធ្វើឡើងនៅសាលាបឋម និងមធ្យមសិក្សាចំនួន១៩០នៅស្រុកដែលក្រីក្របំផុតក្នុងរដ្ឋញូវជឺស៊ីប្រទេសអាមេរិចនៅឆ្នាំ២០០២។ ការសិក្សាស្រាវជ្រាវនេះបានបង្ហាញថា ការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពនឹង ត្រូវបានធ្វើឡើងដោយក្រុមធ្វើការសម្រេចចិត្ត ហើយការអនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលនឹងមិនមានបញ្ហាប្រឈមទេ។ ប៉ុន្តែបញ្ហាគឺបណ្តាលមកពីសមាជិកក្រុមធ្វើសេចក្តីសម្រេចចិត្តខ្វះចំណេះដឹង, ជំនាញពាក់ព័ន្ធនិងបទពិសោធន៍ក្នុងការសម្រេចចិត្តលើការងារសាលារៀន (Walker,2002) ។ មូលហេតុស្រដៀងគ្នានេះដែរ តំណាងមាតាបិតាសិស្ស នៅសាលាបឋមសិក្សា២ នៅឃ្វីនឡែន ត្រូវបានគេរាំងមិនឱ្យចូលរួមក្នុងការពិភាក្សា និងការសម្រេចចិត្តសំខាន់ៗរបស់សាលារៀន។ នេះគឺដោយសារតែការខ្វះជំនាញរបស់សមាជិកក្រុមប្រឹក្សា បើយោងតាមការសិក្សាស្រាវជ្រាវមួយរបស់លោក Canston (2001) ។ករណីស្រដៀងគ្នាមួយទៀតកើតឡើងនៅសាលាវិចតូរីយ៉ាចំនួន១៧២ដែលស្រាវជ្រាវដោយលោក(Benjamin& Sheung,1997)។ការលំបាកគឺសមាជិកក្រុមប្រឹក្សាមាតាបិតាសិស្សមិនមានទំនុកចិត្តទាំងស្រុង ក្នុងការពិភាក្សាលើបញ្ហាដូចជាគោលនយោបាយអប់រំ កម្មវិធីសិក្សា និងការជ្រើសរើសបុគ្គលិក។បើយោងតាមសៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន (គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាឆ្នាំ២០១៨) របស់ក្រសួងអប់រំ យុវជន និងកីឡាក៏បានលើកឡើងថា សមត្ថភាពធនធានមនុស្សខ្សោយ គឺជាបញ្ហាប្រឈមជាក់ស្តែងដែលគណៈកម្មការគ្រប់គ្រងសាលារៀន និងនាយកឬ នាយិកាសាលាជួបប្រទះក្នុងការអនុវត្តការគ្រប់គ្រងសាលារៀនកន្លងមក។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១- ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានសិក្សាតាមវិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យ។ កម្រងសំណួរចំនួនពីរប្រភេទត្រូវបានបង្កើតឡើងផ្សេងៗគ្នាដែលរួមមាន ៖ កម្រងសំណួរសម្ភាសន៍សម្រាប់នាយកសាលា និងកម្រងសំណួរបំពេញសម្រាប់លោកគ្រូ-អ្នកគ្រូដែលបង្រៀនមុខវិជ្ជាគោលទាំង៦ (គណិត វិទ្យា គីមីវិទ្យា រូបវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា ភាសាខ្មែរ ) នៅថ្នាក់ទី៧ ទី៨ និងទី៩ នៃសាលាគោលដៅទាំង៤ក្នុងខេត្តបាត់ដំបង។ កម្រងសំណួរទាំង២នេះត្រូវបានបង្កើតឡើងតាមរយៈការអានឯកសារនានា ដែលទាក់ទងនឹងការគ្រប់គ្រងតាមសាលារៀន និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណិតដែលទាក់ទងនឹងប្រធានបទនេះ។

## ៣.២- ទីតាំងនៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទខាងលើនេះ អ្នកសិក្សាស្រាវជ្រាវបានសម្រេចជ្រើសរើសសាលាគោលដៅទាំង ០៤ ក្នុងខេត្តបាត់ដំបងដែលត្រូវបានដាក់ឱ្យអនុវត្តកម្មវិធីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល។ សាលារៀនទាំងនោះរួមមាន៖ វិទ្យាល័យអន្លង់វិល វិទ្យាល័យពេជ្រចិន្តា វិទ្យាល័យរូងជ្រៃ និងវិទ្យាល័យបវេល សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។ មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវជ្រើសរើសយកវិទ្យាល័យទាំង០៤ ខាងលើនោះមកធ្វើការសិក្សាស្រាវជ្រាវ គឺដោយសារសលាទាំងបួននោះនៅក្នុងខេត្តដែលអ្នកស្រាវជ្រាវកំពុងរស់នៅអាចសម្របសម្រួលច្រើនដល់ពេលវេលារបស់អ្នកស្រាវជ្រាវ។

## ៣.៣- ការជ្រើសរើសសំណាក

| ល-រ | ក្រុមគោលដៅ | ចំនួនអ្នកចូលរួម |
|---|---|---|
| ០១ | នាយកសាលា | ០៤នាក់ |
| ០២ | គ្រូបង្រៀន | ៥០នាក់ |

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះអ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់វិធីជ្រើសរើសសំណាកឱ្យឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ ដោយកំណត់យកតែសំណាកណាដែលទាក់ទងនឹងសំណួរស្រាវជ្រាវ និងមានប្រយោជន៍ដើម្បីទទួលបានទិន្នន័យចាំបាច់និងជាក់លាក់ ជាពិសេសអាចឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវប្រធានបទខាងលើ ។ សំណាកដែលអ្នកសិក្សាលើកយកមកស្រាវជ្រាវមានពីរប្រភេទគឺ៖ នាយកឬនាយិកាចំនួន ០៤

នាក់ លោកគ្រូ/អ្នកគ្រូបង្រៀនមុខវិជ្ជាគោលចំនួន ៥០ នាក់ មកពីសាលាគោលដៅទាំង៤ នៃខេត្តបាត់ដំបង។ ប្រភេទសំណាកទី១ គឺជ្រើសរើសលោកនាយក/លោកស្រីនាយិកាចំនួន ០៤ នាក់ ដើម្បីសម្ភាសពួកគាត់ដោយប្រើកម្រងសំណួរសម្រាប់នាយកសាលាទាក់ទងនឹងប្រធានបទ។ សំណាកទី២ គឺជ្រើសរើសគ្រូបង្រៀនមុខវិជ្ជាគោលនៃសាលាគោលដៅនៅកម្រិតមធ្យមសិក្សាបឋមភូមិចំនួន ៥០នាក់ ដើម្បីឱ្យពួកគាត់បំពេញនូវកម្រងសំណួរស្តីពីលំនាំនៃការអនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ព្រមទាំងបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីនេះផងដែរ។ ទាំងកម្រងសំណួរសម្រាប់សម្ភាសនាយក និងកម្រងសំណួរសម្រាប់គ្រូបង្រៀន គឺផ្តោតលើចំណុចសំខាន់៤គឺ ៖ (១).ការគ្រប់គ្រងរដ្ឋបាល (២.)ការគ្រប់គ្រងការរៀន និងបង្រៀន (៣.)ការគ្រប់គ្រងបុគ្គលិក និង (៤.) ការគ្រប់គ្រងហិរញ្ញវត្ថុ។ ការជ្រើសរើសមុខសញ្ញានៃភាគសំណាកពីរប្រភេទមកធ្វើការស្រាវជ្រាវនេះ គឺដើម្បីផ្ទៀងផ្ទាត់គ្នា ថាតើចម្លើយដែលបានមកពីភាគសំណាកទាំងពីរមានភាពសុក្រឹតឬមិនសុក្រឹត។

## ៣.៤- ឧបករណ៍នៃការស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យឱ្យបានជាក់លាក់ អ្នកសិក្សាស្រាវជ្រាវបានបង្កើតទម្រង់សំណួរស្រាវជ្រាវចំនួន ២ប្រភេទដើម្បីឆ្លើយតបទៅនឹងវត្ថុបំណង និងសំណួរស្រាវជ្រាវដែលរួមមាន៖ (១). ទម្រង់កម្រងសំណួរសម្ភាសន៍សម្រាប់នាយកឬនាយិកា និង (២). ទម្រង់កម្រងសំណួរបំពេញសម្រាប់លោកគ្រូ អ្នកគ្រូ។ ទម្រង់កម្រងសំណួរសម្រាប់នាយកឬនាយិកាសាលា គឺអ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៖ ព័ត៌មានទូទៅទាក់ទងនឹងឈ្មោះសាលា រយៈពេលបម្រើការងាររបស់ពួកគាត់ជានាយក ឬនាយិកាសាលា កម្រិតសញ្ញាបត្រ និង មាន៤ចំណុចសំខាន់ៗដែលទាក់ទងនឹងការគ្រប់គ្រងតាមសាលារៀនគឺ ៖ (១).ការគ្រប់គ្រងរដ្ឋបាល (២).ការគ្រប់គ្រងការរៀន និងបង្រៀន (៣).ការគ្រប់គ្រងបុគ្គលិក និង (៤).ការគ្រប់គ្រងហិរញ្ញវត្ថុ ។ ទម្រង់សំណួរបំពេញសម្រាប់លោកគ្រូ/អ្នកគ្រូមុខវិជ្ជាគោល គឺត្រូវបានបែងចែកជា ៖ ព័ត៌មានទូទៅទាក់ទងនឹងឈ្មោះសាលា កម្រិតថ្នាក់ដែលគាត់បង្រៀន និងឯកទេស ហើយក៏មាន ៤ ចំណុចសំខាន់ៗដែលទាក់ទងនឹងការគ្រប់គ្រងតាមសាលារៀន ៖ ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងការរៀន និងបង្រៀន ការគ្រប់គ្រងបុគ្គលិក និងការគ្រប់គ្រងហិរញ្ញវត្ថុ។

## ៣.៥-ដំណាក់កាលនៃការប្រមូលទិន្នន័យ

ក្រោយពីទទួលបានការណែនាំ និងការឯកភាពពីគ្រូណែនាំ ព្រមទាំងទទួលបានលិខិតឧទ្ទេសនាមលេខ ១១៩ វជអ. ជក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ និងលិខិតស្នើសុំលេខ ១៨៨៥ អយក.វជអ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ស្នើទៅកាន់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបងស្តីពីការសុំជួយសហការ និងសម្របសម្រួលដល់ការចុះប្រមូលព័ត៌មាននៅតាមវិទ្យាល័យគោលដៅក្នុងខេត្តបាត់ដំបង អ្នកសិក្សាស្រាវជ្រាវ បានរៀបចំចងក្រង និងធ្វើផែនការដើម្បីចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅទាំង៤។ មូលហេតុនៃការស្នើសុំទៅកាន់មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង ដោយសារសាលាគោលដៅដែលយកមកធ្វើការស្រាវជ្រាវទាំងនោះ គឺស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង។ បន្ទាប់ពីទទួលបានការឆ្លើយតបពីមន្ទីរអប់រំ យុវជន និងកីឡា តាមរយៈចំណាររបស់ប្រធានមន្ទីរលើលិខិតស្នើសុំ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការអនុញ្ញាតឱ្យទៅប្រមូលទិន្នន័យនៅតាមសាលាគោលដៅ អ្នកសិក្សាស្រាវជ្រាវ បានរៀបចំផែនការ ចុះទៅធ្វើការទំនាក់ទំនងជាមួយនាយកសាលា ដើម្បីសុំការសហការ និងកំណត់កាលបរិច្ឆេទក្នុងការណាត់ជួបសម្ភាសន៍លោកនាយក/លោកស្រីនាយិកា បន្ទាប់មកទើបចែកជូនកម្រងសំណួរដល់គ្រូបង្រៀនមុខវិជ្ជាគោលថ្នាក់ទី៧ ទី៨ និងទី៩ ដើម្បីបំពេញ។ អ្នកសិក្សាស្រាវជ្រាវក៏បានពន្យល់ពីដំណើរការទាំងមូល និងបានពិភាក្សាជាមួយថ្នាក់ដឹកនាំសាលាអំពីគោលបំណង ផែនការទាំងមូលនៃការស្រាវជ្រាវ ព្រមទាំងសារប្រយោជន៍នៃការស្រាវជ្រាវនេះដែរ។ ក្រោយពីនាយកសាលា បានពិនិត្យលិខិតអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង ក្នុងកិច្ចការស្រាវជ្រាវនេះរួចរាល់ហើយ គាត់ក៏បានអនុញ្ញាតឱ្យរៀបចំការប្រមូលទិន្នន័យតាមផែនការដែលបានឯកភាពនៃដំណាក់កាលនីមួយៗ ។ មុននឹងចុះប្រមូលទិន្នន័យជាក់ស្តែង អ្នកសិក្សាស្រាវជ្រាវបានរៀបចំសាកល្បងលើកម្រងសំណួរទាំងអស់នោះនៅតាមសាលាមួយដែលស្ថិតនៅជិតជាងគេក្នុងខេត្តបាត់ដំបង ។ គោលបំណងនៃការសាកល្បងកម្រងសំណួរទាំងនេះ គឺដើម្បីធានាប្រសិទ្ធភាព និងភាពជឿជាក់បាននៃកម្រងសំណួរទាំងនោះ ថាតើវាមានសំណួរណាខ្លះដែលគួរកែលម្អ និងចង់ដឹងថាវាអាចយកមកប្រមូលទិន្នន័យជាក់ស្តែងបានឬទេ ។ ក្រោយពីសាកល្បងលើកម្រងសំណួររួចរាល់ អ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា ការសាកល្បងនេះពិតជាបានផល និងមានសារប្រយោជន៍មែន ព្រោះអ្នកសិក្សាស្រាវជ្រាវ បានរកឃើញបញ្ហា និងចំណុចខ្វះខាតមួយចំនួន។ ក្រោយពីរកឃើញនូវចំណុចខ្វះខាតលើកម្រងសំណួររួចមក អ្នកសិក្សាស្រាវបានសុំយោបល់ និងទទួលការណែនាំ

កែលម្អបន្ថែមពីសាស្ត្រាចារ្យដឹកនាំ ទើបអ្នកសិក្សាស្រាវជ្រាវចាប់ផ្តើមចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅទាំង៩។

### ៣.៦-ការវិភាគទិន្នន័យ

ចំពោះកិច្ចការស្រាវជ្រាវនេះអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្ន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលបានពីគ្រូបង្រៀនមុខវិជ្ជាគោលតាមសាលាគោលដៅទាំងអស់ ត្រូវបានវិភាគដាច់ដោយឡែកពីទិន្នន័យបែបគុណវិស័យ ដោយប្រើកម្មវិធី SPSS សម្រាប់បញ្ចូលទិន្នន័យ និងវិភាគទិន្នន័យចេញជាភាគរយ។ បន្ទាប់មកអ្នកស្រាវជ្រាវក៏បានប្រើកម្មវិធី Ms. Excel សម្រាប់សង់ក្រាប និងបកប្រែធាតុសំណាកនីមួយៗជាភាសាខ្មែរ។ នៅក្នុងដំណាក់កាលនៃការវិភាគទិន្នន័យនេះ អ្នកសិក្សាស្រាវជ្រាវ បានធ្វើការវិភាគទិន្នន័យដែលប្រមូលបានតាមរយៈការសម្ភាសន៍លោកនាយកសាលា និងធ្វើការផ្ទៀងផ្ទាត់ជាមួយទិន្នន័យដែលទទួលបានពីការបំពេញកម្រងសំណួររបស់លោកគ្រូអ្នកគ្រូ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់លាស់អំពីកម្រិតនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅសាលាមធ្យមសិក្សាបឋមភូមិនៅតាមសាលាគោលដៅទាំង៩ក្នុងខេត្តបាត់ដំបង។ ចំណែកការវិភាគទិន្នន័យបែបគុណវិស័យ គឺអ្នកសិក្សាស្រាវជ្រាវបានប្រមូលផ្តុំចម្លើយរបស់ភាគីពាក់ព័ន្ធដែលទទួលបានតាមរយៈការសម្ភាសន៍នាយកសាលា ឬនាយិកាសាលា និងកម្រងសំណួរបើកសម្រាប់គ្រូបង្រៀន ដើម្បីរកឱ្យឃើញពីបញ្ហាប្រឈមនានាក្នុងការអនុវត្តគម្រោងនេះនៅសាលាគោលដៅក្នុងខេត្តបាត់ដំបង ទៅលើការគ្រប់គ្រង៤ចំណុច ( ការគ្រប់គ្រងរដ្ឋបាល,ការគ្រប់គ្រងការរៀន និងបង្រៀន,ការគ្រប់គ្រងបុគ្គលិក,ការគ្រប់គ្រងហិរញ្ញវត្ថុ) ហើយដែលឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវ ។ ហើយអ្នកស្រាវជ្រាវបានលើកយកបញ្ហាប្រឈមមកបង្ហាញនៅផ្នែកចុងក្រោយនៃចំណុចនីមួយៗ។ បន្ទាប់មក អ្នកស្រាវជ្រាវក៏បានលើកជាអនុសាសន៍ និងសំណូមពរចំពោះក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ការិយាល័យអប់រំយុវជន និងកីឡា ស្រុក សាលា និងលោកគ្រូ/អ្នកគ្រូ ដើម្បីជ្រាបជាព័ត៌មានសម្រាប់ការកែទម្រង់ និងស្វែងរកដំណោះស្រាយចំពោះបញ្ហាដែលកើតមានឡើងដើម្បីជំរុញការអនុវត្តការគ្រប់គ្រងតាមសាលារៀនឱ្យកាន់តែមានប្រសិទ្ធភាព។

## ៣.៧.ក្រមសីលធម៌នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវបានផ្តោតការយកចិត្តទុកដាក់ពីក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវចំពោះភាគីពាក់ព័ន្ធ ពីព្រោះចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធានាប្រសិទ្ធភាពនៃការស្រាវជ្រាវ ក៏ដូចជាបង្កើននូវភាពជឿជាក់ និងភាពទុកចិត្តបានចំពោះអ្នកចូលរួមផ្តល់ចម្លើយ។ ម្យ៉ាងវិញទៀត ទិន្នន័យផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវនេះ គឺគ្មានភាពលម្អៀង។ អ្នកសិក្សាស្រាវជ្រាវ បានរក្សាក្រមសីលធម៌ខ្ពស់ក្នុងដំណាក់កាលនីមួយៗមុនពេលស្រាវជ្រាវដូចជា៖ សុំការអនុញ្ញាតដោយធ្វើលិខិតស្នើសុំពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងសាលាគោលដៅដើម្បីសុំការឯកភាព និងការសហការនៅក្នុងអំឡុងពេលស្រាវជ្រាវនេះ។ អ្នកសិក្សាស្រាវជ្រាវបានណែនាំពីគោលបំណង និងសារប្រយោជន៍នៃការសិក្សាស្រាវជ្រាវដល់អ្នកចូលរួមឱ្យបានជ្រាប និងចូលរួមផ្តល់ចម្លើយដែលអាចទុកចិត្តបាន និងរក្សាភាពអនាមិកនូវរាល់ចម្លើយរបស់អ្នកចូលរួម និងក្រោយពេលស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវ បានរក្សាភាពស្មោះត្រង់ចំពោះការបញ្ចូលទិន្នន័យនូវចម្លើយរបស់អ្នកចូលរួម ដោយមិនបំផ្លើស និងបំពេញបន្ថែមលើចំណុចណាមួយឡើយ។ ការធ្វើបែបនេះ គឺមានន័យថា ការសិក្សាស្រាវជ្រាវនេះនឹងទទួលបានលទ្ធផលល្អនិងជឿទុកចិត្តបានហើយក៏ជាភស្តុតាងមួយបញ្ជាក់ពីការចុះទៅប្រមូលទិន្នន័យប្រកបដោយភាពត្រឹមត្រូវនិងក្រមសីលធម៌ខ្ពស់ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ
# និងការពិភាក្សា

## ជំពូកទី៤

នៅក្នុងជំពូកទី៤ នេះនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ការបកស្រាយ និងការពិភាក្សានូវអ្វីដែលបានរកឃើញតាមរយៈការសម្ភាសលោកនាយកសាលា និងតាមរយៈការបំពេញកម្រងសំណួររបស់លោកគ្រូអ្នកគ្រូ ដែលបង្រៀនមុខវិជ្ជាគោលថ្នាក់ទី៧ ទី៨ និងទី៩ ។ ហើយរាល់ចំណុចសំខាន់ៗផ្សេងទៀតដែលទាក់ទងនឹងប្រធានបទ ត្រូវបានលើកយកមកបកស្រាយ និងពិភាក្សាដូចខាងក្រោម ៖

### ៤.១. ការគ្រប់គ្រងរដ្ឋបាល ៖

#### ៤.១.១.ការបង្ហាញតម្លាភាពរបស់នាយកសាលា

ក្រាបទី១៖ការបង្ហាញតម្លាភាពរបស់នាយក




តាមរយៈក្រាហ្វិកទី១ បានបង្ហាញឱ្យឃើញថា លោកនាយកមានតម្លាភាពល្អក្នុងការគ្រប់គ្រង ដោយគ្រូបង្រៀនចំនួន ១០០% បានឆ្លើយដូចគ្នាថាលោកនាយកពិតជាបានបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស) ការប្រជុំពិភាក្សាជាមួយលោកគ្រូ/អ្នកគ្រូនិងអ្នកពាក់ព័ន្ធ ព្រមទាំងបានបិទផ្សាយទិន្នន័យ និងព័ត៌មានផ្សេងៗដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ។តាមការរៀបរាប់របស់លោកនាយកសាលា មុនពេលចាប់ផ្តើមគម្រោងពួកគាត់បានប្រជុំបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន

(គ.គ.ស) តាមរយៈការបោះឆ្នោត ដែលក្នុងនោះមានសមាជិកចាប់ពី៦រូបឡើងទៅ (ប្រធាន ១រូប អនុប្រធាន២ រូប និងសមាជិក៣រូបឬលើស)ថែមទាំងបានពន្យល់ណែនាំអំពីតួនាទីរបស់ គ.គ.ស ផងដែរ។ រាល់ការធ្វើសកម្មភាពនានា លោកនាយកមានការប្រជុំពិភាក្សាជាមួយលោកគ្រូ/អ្នកគ្រូ និងអ្នកពាក់ព័ន្ធផ្សេងៗ ដូចជាការធ្វើផែនការកែលម្អសាលារៀនគឺធ្វើនៅដើមខែវិច្ឆិកាជារៀងរាល់ឆ្នាំសម្រាប់យកទៅអនុវត្តនៅក្នុងឆ្នាំសិក្សាបន្ទាប់។ លោកនាយកក៏បានបិទផ្សាយទិន្នន័យ និងព័ត៌មានផ្សេងៗដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ហើយមានផែនការចំណូល ចំណាយ ពេលប្រជុំរួមដើមឆ្នាំសិក្សា និងបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មានសាលានិងនៅសាលាឃុំ៣ខែម្តង។

### ៤.១.២. ការចូលរួមរបស់គ្រូបង្រៀនក្នុងការរៀបចំផែនការផ្សេងៗ

ក្រាបទី២៖ ការចូលរួមរបស់គ្រូបង្រៀនក្នុងការរៀបចំផែនការផ្សេងៗ




ទិន្នន័យដែលបង្ហាញក្នុងក្រាហ្វិកទី២នេះបានបញ្ជាក់ថាគ្រូបង្រៀនចំនួន៩២% ធ្លាប់បានចូលរួមជាមួយគណៈគ្រប់គ្រង និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការរៀបចំធ្វើផែនការផ្សេងៗ មានគ្រូបង្រៀនតែ ៨% ប៉ុណ្ណោះដែលពុំធ្លាប់បានចូលរួម។តាមការអះអាងរបស់លោកនាយកសាលាគោលដៅទាំង៤ ថាពួកគាត់បានអញ្ជើញអ្នកពាក់ព័ន្ធចូលរួមក្នុងការរៀបចំផែនការមានដូចជា៖ គណៈគ្រប់គ្រង, អាជ្ញាធរ( មេភូមិ ),គណៈកម្មការគ្រប់គ្រងសាលារៀន,តំណាងអាណាព្យាបាលសិស្ស, គ្រូបង្រៀនគ្រប់មុខវិជ្ជា,និងគ្រូបង្គោលថ្នាក់ជាតិ( ជួយសម្របសម្រួលពេលចាប់ផ្តើមកម្មវិធីដំបូង)។

ហើយលោកនាយក និងគ្រូបង្រៀនផ្សេងៗទៀត បានឱ្យដឹងថាមានគ្រូមួយចំនួនតូចតែប៉ុណ្ណោះ ដែលពុំសូវចូលរួមដោយសារពួកគាត់ជាប់ធុរៈផ្ទាល់ខ្លួន។

### ៤.១.៣. និតិវិធីរបស់នាយកក្នុងការគៀរគរថវិកា

ក្រាបទី៣ ៖ និតិវិធីរបស់នាយកក្នុងការប្រមូលមូលនិធិ




ទិន្នន័យខាងលើបានបង្ហាញថាគ្រូបង្រៀនចំនួន ៩៦% បានបញ្ជាក់ថាលោកនាយកបានសម្របសម្រួលក្នុងការរៀបចំប្រមូលមូលនិធិសម្រាប់សាលារៀន ហើយគ្រូបង្រៀនតែ ៤% ប៉ុណ្ណោះដែលបានឆ្លើយថាលោកនាយកពុំធ្លាប់សម្របសម្រួលក្នុងការងារនេះ ។ បើតាមការបញ្ជាក់ពីលោកនាយកបានឱ្យដឹងថាពួកគាត់ ព្រមទាំងលោកគ្រូ អ្នកគ្រូពិតជាបានខិតខំគៀរគរថវិកាសម្រាប់អភិវឌ្ឍសាលារៀនក្រោយពេលប្រជុំជាមួយអ្នកពាក់ព័ន្ធពីថវិកាគ្រោង ថវិកាដែលមាន និងថវិកាដែលខ្វះ ដែលត្រូវការការគាំទ្រពីសហគមន៍ ។ ដូច្នេះទើបលោកនាយកមានការរៀបចំគៀរគរថវិកាពីសប្បុរសជន , មាតាបិតាសិស្ស,បុណ្យផ្កាអង្គាសប្រាក់ , អតីតសិស្ស, អង្គការក្រៅរដ្ឋាភិបាលនានា, សមាគមចិន និងផាស៊ីសាលាជាដើម ។

## ៤.១.៤. ការប្រមូលព័ត៌មានពីការវាយតម្លៃគ្រូ សិស្ស និង សាលារៀន

ក្រាបទី៤ ៖ ការប្រមូលព័ត៌មានពីការវាយតម្លៃគ្រូ សិស្ស និង សាលារៀន




ទិន្នន័យក្នុងក្រាហ្វិកទី៤ នេះបានបង្ហាញថាលោកនាយកពិតជាបានរៀបចំប្រមូលព័ត៌មានផ្សេងៗទាក់ទងនឹងការវាយតម្លៃគ្រូ ការវាយតម្លៃសិស្ស និងការវាយតម្លៃសាលារៀន ដោយមានគ្រូបង្រៀនចំនួនដល់ទៅ៩៤% បានបញ្ជាក់ពីកិច្ចការនេះ ។ លោកនាយកក៏បានលើកឡើងពីការងារនេះលម្អិតផងដែរ៖

- ❖ ការវាយតម្លៃសិស្សគឺធ្វើតេស្តស្តង់ដានៅដើមឆ្នាំសិក្សាម្តង បន្ទាប់មកធ្វើប្រចាំខែ និងប្រចាំឆមាស ដើម្បីប្រៀបធៀបលទ្ធផលសិស្សពី១ខែទៅ១ខែ ។
- ❖ ការវាយតម្លៃគ្រូគឺធ្វើឡើងនៅចុងឆ្នាំសិក្សា៖ការពិនិត្យវត្តមាន(គ្រូកត់ត្រាខ្លួនឯង,សិស្សកត់,គ្រូដើរត្រួតពិនិត្យ),កិច្ចតែងការ,ការធ្វើអធិការកិច្ច,ឥរិយាបថ,រដ្ឋបាលថ្នាក់រៀន,ការចូលរួមជាមួយគណៈគ្រប់គ្រង។
- ❖ ការវាយតម្លៃសាលារៀនគឺធ្វើនៅដើមឆ្នាំសិក្សា៖ ការពិនិត្យនិងតាមដានការអនុវត្តដោយផ្អែកលើផែនការប្រតិបត្តិប្រចាំត្រីមាស និងសាកសួរលោកគ្រូ អ្នកគ្រូពេលប្រជុំរួម។

## ៤.១.៥. ការលើកទឹកចិត្តគ្រូបង្រៀនដែលសកម្ម

ក្រាបទី៥ ៖ ការលើកទឹកចិត្តគ្រូដែលសកម្ម




ក្រាហ្វិកនេះបានបង្ហាញថាការលើកទឹកចិត្តរបស់លោកនាយកចំពោះបុគ្គលិកដែលសកម្មនៅមានកម្រិត ព្រោះគ្រូបង្រៀនចំនួន ៥៦% បានឆ្លើយថាលោកនាយកធ្លាប់បានផ្តល់ការលើកទឹកចិត្ត តាមរយៈការផ្តល់ប័ណ្ណសរសើរ ឬការផ្តល់រង្វាន់ ដល់បុគ្គលិកដែលបំពេញការងារបានល្អ រីឯគ្រូបង្រៀនចំនួន ៤៤% ទៀតបានបញ្ជាក់ថាលោកនាយកពុំធ្លាប់ ផ្តល់ការលើកទឹកចិត្តបែបនេះទេ។បើយោងតាមប្រសាសន៍របស់លោកនាយកសាលាគោលដៅទាំង៤ ការលើកទឹកចិត្តនៅតាមសាលានីមួយៗគឺពុំដូចគ្នាទេ គឺអាស្រ័យទៅតាមលទ្ធភាពរបស់សាលារៀងៗខ្លួន។លោកនាយកវិទ្យាល័យបវេល និងវិទ្យាល័យពេជ្រចិន្តាបានផ្តល់ជាបណ្ណសរសើរ និងថវិកាតិចតួចដល់គ្រូបង្រៀនដែលបំពេញការងារបានល្អប្រសើរ។ ចំណែកលោកនាយកវិទ្យាល័យរូងជ្រៃ និងវិទ្យាល័យអន្លង់វិល មានការលើកទឹកចិត្តបុគ្គលិកដែលសកម្ម តាមរយៈការសរសើរដោយពាក្យសម្តីនៅក្នុងអង្គប្រជុំប៉ុណ្ណោះ។

### ៤.១.៦. វិធានការរដ្ឋបាលចំពោះគ្រូដែលអសកម្ម

ក្រាបទី៦៖ ការចេញវិធានការរដ្ឋបាលដល់គ្រូដែលអសកម្ម




យោងតាមទិន្នន័យខាងលើ យើងឃើញថាលោកនាយកពិតជាបានអនុវត្តវិធានការរដ្ឋបាលដល់គ្រូដែលអសកម្មការងារ ក្នុងនោះមានគ្រូបង្រៀនចំនួន ៧០% បញ្ជាក់ថាលោកនាយកធ្លាប់បានចាត់វិធានការរដ្ឋបាលចំពោះបុគ្គលិកដែលអសកម្មការងារ ហើយមានគ្រូបង្រៀនចំនួន ៣០% ប៉ុណ្ណោះដែលបានឆ្លើយថាលោកនាយកពុំធ្លាប់ចាត់វិធានការរដ្ឋបាលបែបនេះទេ។បើតាមប្រសាសន៍លោកនាយកសាលា មានតែលោកនាយក៣នាក់ប៉ុណ្ណោះដែលបានអនុវត្តវិធានការរដ្ឋបាលចំពោះបុគ្គលិកអសកម្មដូចជា ៖ ការស្តីបន្ទោសឬការធ្វើកិច្ចសន្យាជាដើម។ចំណែកលោកនាយកវិទ្យាល័យពេជ្រចិន្តាវិញមានតែការជំរុញ និងលើកទឹកចិត្តបុគ្គលិកដែលអសកម្ម ឱ្យចូលរួមឱ្យបានច្រើនជាងមុន។ទន្ទឹមនឹងលំនាំនៃការអនុវត្តការគ្រប់គ្រងរដ្ឋបាលត្រូវបានរកឃើញដូចបានរៀបរាប់ខាងលើក៏ដោយ ក៏ការស្រាវជ្រាវនេះរកឃើញនូវបញ្ហាប្រឈមមួយចំនួនផងដែរដូចជា៖

- ការខ្វះសម្ភារៈផ្នែករដ្ឋបាល ផ្នែកពិសោធន៍ និងសៀវភៅសិក្សាគោល
- ការខ្វះការចូលរួមពីលោកគ្រូ អ្នកគ្រូមួយចំនួនដោយសារពួកគាត់ភាគច្រើនរវល់កិច្ចការផ្ទាល់ខ្លួន
- អាណាព្យាបាលសិស្សមិនសូវចូលរួមក្នុងការប្រជុំពិភាក្សាអំពីលទ្ធផលសិក្សារបស់កូន ព្រោះពួកគាត់ភាគច្រើនមិននៅផ្ទះ និងមានការរវល់ច្រើន។
- អាណាព្យាបាលសិស្ស និងអាជ្ញាធរមិនសូវយល់អំពីគម្រោង ។
- សមាជិកគណៈកម្មាការគ្រប់គ្រងសាលារៀនមិនសូវសកម្ម(មានតែ២នាក់ដែលសកម្ម)
- ការលើកទឹកចិត្តដល់គ្រូបង្រៀនដែលសកម្មការងារនៅមានកម្រិត

## ៤.២. ការគ្រប់គ្រងការរៀន និងបង្រៀន

### ៤.២.១. ការរៀបចំកិច្ចតែងការបង្រៀន

ក្រាបទី៧៖ការរៀបចំកិច្ចតែងការបង្រៀន



ទិន្នន័យក្នុងក្រាហ្វិកខាងលើ បានបង្ហាញថាលោកគ្រូ / អ្នកគ្រូភាគច្រើនរៀបចំកិច្ចតែងការបង្រៀនបានល្អបង្គួរ ចំនួន ៧៨% និងរៀបចំកិច្ចតែងការបានល្អ ចំនួន១០% មានតែគ្រូបង្រៀន ១២%ប៉ុណ្ណោះដែលរៀបចំកិច្ចតែងការបង្រៀនបានតិចតួចនៅឡើយ។លោកនាយកសាលាគោលដៅទាំងអស់មានប្រសាសន៍ឱ្យដឹងថានៅដើមខែវិច្ឆិកា មានការប្រជុំក្រុមបច្ចេកទេសតាមមុខវិជ្ជាដើម្បីកំណត់ចំនួនកិច្ចតែងការដែលត្រូវធ្វើប្រចាំត្រីមាស រួចវាយតម្លៃនៅចុងត្រីមាសនីមួយៗ។ លោកនាយកក៏បានឱ្យដឹងថាគ្រូបង្រៀនភាគច្រើនបានរៀបចំរដ្ឋបាលថ្នាក់រៀន និងកិច្ចតែងការបង្រៀនរបស់ពួកគាត់បានល្អប្រសើរ មានតែមួយចំនួនតូចប៉ុណ្ណោះដែលនៅមានចំណុចខ្វះខាត។

### ៤.២.២. ការដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ

ក្រាបទី៨៖ការដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ




ទិន្នន័យក្រាហ្វិកទី៨ បានបង្ហាញថាគ្រូបង្រៀនដែលបានដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើញឹកញាប់មានចំនួន ៥៦% ហើយគ្រូបង្រៀនចំនួន ២៨% ទៀតបានដាក់កិច្ចការផ្ទះឱ្យសិស្សអនុវត្តជាប្រចាំផងដែរ គ្រូបង្រៀនដែលបានដាក់កិច្ចការផ្ទះម្តងម្កាលមានចំនួន ១៦% ។បើតាមទិន្នន័យដែលបានពីការសម្ភាសន៍លោកនាយកសាលាគោលដៅទាំង៤ បានឱ្យដឹងថាលោកគ្រូអ្នកគ្រូមានការប្រជុំរៀងរាល់ដើមត្រីមាស ដើម្បីកំណត់ចំនួនកិច្ចការផ្ទះដែលត្រូវដាក់ឱ្យសិស្សធ្វើ ដោយមានភ្ជាប់តារាងបំពេញជូនលោកនាយកផង ដើម្បីប្រជុំបូកសរុបនៅរាល់ដំណាច់ត្រីមាស។កិច្ចការផ្ទះដែលត្រូវឱ្យ

សិស្សធ្វើអាចជាលំហាត់ឬជាគម្រោងស្រាវជ្រាវទៅតាមមុខវិជ្ជាៈ មុខវិជ្ជាវិទ្យាសាស្ត្រ(លំហាត់) និងមុខវិជ្ជាសង្គម(គម្រោងស្រាវជ្រាវ)។

### ៤.២.៣.ការប្រជុំបច្ចេកទេស

ក្រាបទី៩៖ការប្រជុំបច្ចេកទេស




ទិន្នន័យខាងលើបានបង្ហាញថា គ្រូបង្រៀនចំនួន ៩០% បានបញ្ជាក់ថាពួកគាត់មានការប្រជុំបច្ចេកទេសទៀងទាត់ ហើយគ្រូបង្រៀនតែ ១០% ប៉ុណ្ណោះដែលពុំមានការប្រជុំបច្ចេកទេសបាទៀងទាត់។តាមរយៈទិន្នន័យដែលបានពីការសម្ភាសន៍លោកនាយកសាលាគោលដៅទាំងអស់បានឱ្យដឹងថាលោកគ្រូ អ្នកគ្រូមានការប្រជុំបច្ចេកទេសជារៀងរាល់ខែ ហើយក្នុងការប្រជុំពួកគាត់បានពិភាក្សាគ្នាពីការធ្វើកិច្ចតែងការបង្រៀន ផែនការបង្រៀន ផ្លាស់ប្តូរបទពិសោធគ្នាពីបច្ចេកទេសបង្រៀន និងវិធីសាស្ត្រថ្មីៗ ការរៀបចំតេស្តស្តង់ដាប្រចាំខែ និងស្វែងរកវិធីដើម្បីជួយសិស្សរៀនយឺតជាដើម។

## ៤.២.៤. ការប្រឹក្សាយោបល់ជាមួយមាតាបិតាសិស្សរៀនយឺត

ក្រាបទី១០៖ការប្រឹក្សាយោបល់ជាមួយមាតាបិតាសិស្សរៀនយឺត




ទិន្នន័យក្នុងក្រាហ្វិកទី១០នេះ បានបង្ហាញថាគ្រូបង្រៀនចំនួន ៧៦% បញ្ជាក់ថាពួកគាត់ធ្លាប់បានប្រជុំពិភាក្សាយោបល់ជាមួយ អាណាព្យាបាលសិស្សដែលរៀនយឺត។ចំណែកគ្រូបង្រៀន ២៤% ទៀតបានបញ្ជាក់ថាពួកគាត់មិនដែលធ្លាប់ជួបប្រឹក្សាយោបល់ជាមួយមាតាបិតាសិស្សទេ ដោយពួកគាត់ពុំមែនជាគ្រូបន្ទុកថ្នាក់។ លោកនាយកសាលាគោលដៅទាំងអស់បានឱ្យដឹងថាលោកគ្រូ អ្នកគ្រូដែលកាន់បន្ទុកថ្នាក់ និងគណៈគ្រប់គ្រងសាលា និងគ.គ.ស ប្រជុំប្រឹក្សាយោបល់ជាមួយអាណាព្យាបាលសិស្សរៀនយឺតនៅដើមឆ្នាំសិក្សាម្តង និងនៅពេលចាំបាច់ ។សាលាខ្លះលោកនាយកបានបញ្ជាក់ថាការប្រជុំនេះធ្វើឡើង១សប្តាហ៍ម្តង (មាតាបិតាសិស្សមួយកម្រិត) នៅសាលាខ្លះ១ខែទៅ២ខែម្តង។ការប្រជុំនេះគឺជម្រាបពួកគាត់ពីលទ្ធផលសិក្សារបស់សិស្ស ហើយសុំការជួយជ្រោមជ្រែងពីមាតាបិតាសិស្សដែលរៀនយឺត ឱ្យជំរុញកូនធ្វើកិច្ចការផ្ទះបន្ថែមទៀត។

## ៤.២.៥. ចំនួនបន្ទប់សិក្សារបស់សិស្ស

ក្រាបទី១១៖ចំនួនបន្ទប់សិក្សាសម្រាប់សិស្ស




ទិន្នន័យខាងលើបង្ហាញថាចំនួនបន្ទប់សិក្សាគឺនៅមានការខ្វះខាតនៅឡើយ គ្រូបង្រៀនចំនួន ៦៤% បានបញ្ជាក់ថាសាលារៀនរបស់គាត់ពុំមានបន្ទប់គ្រប់គ្រាន់ទេ ។លោកនាយកវិទ្យាល័យបវេល និងលោកនាយកវិទ្យាល័យអន្លង់វិលបានលើកឡើងពីបញ្ហាខ្វះបន្ទប់រៀនសម្រាប់សិស្ស ដូចជានៅវិទ្យាល័យបវេល សិស្សមានទៅដល់៥៤ថ្នាក់ ប៉ុន្តែមានបន្ទប់សិក្សាតែ៣៩បន្ទប់ប៉ុណ្ណោះ។ ដូច្នេះតម្រូវឱ្យសិស្សត្រូវឆ្លាស់វេនសិក្សា។ក្នុងការគ្រប់គ្រងការរៀននិងបង្រៀននេះជួបបញ្ហាមួយចំនួនដូចជា៖

- ខ្វះបន្ទប់សិក្សា(ព្រោះសិស្សច្រើន)។ពេលប្រឡងតេស្តស្តង់ដាប្រចាំខែ ដូច្នេះសិស្សត្រូវប្រឡងពីរកម្រិតបញ្ចូលគ្នា(សិស្សថ្នាក់ទី៧ចំនួន២៥នាក់ ប្រឡងជាមួយសិស្សថ្នាក់ទី៩ ឬទី៨ចំនួន២៥នាក់)។
- សិស្សថ្នាក់ទី១០ និងទី១១ ត្រូវខាតម៉ោងសិក្សាពេលប្រឡងតេស្តស្តង់ដាថ្នាក់ទី៧ ទី៨ និងទី៩
- សមត្ថភាពសិស្សមួយចំនួនធំនៅខ្សោយ(ជាក់ស្តែងលទ្ធផលប្រឡងសិស្ស៥០នាក់ ជាប់តិចជាង២០នាក់)

- សិស្សរៀនមេរៀនមិនស្មើគ្នា ពេលចេញតេស្តស្តង់ដា សិស្សខ្លះបានរៀនសិស្សខ្លះមិនទាន់បានរៀនដល់មេរៀននោះទេ
- សិស្សរៀនយឺតមានចំនួនច្រើន(ប្រហែល២០%)
- សិស្សខ្វះការយកចិត្តទុកដាក់ក្នុងការសិក្សា
- អត្រាបោះបង់ការសិក្សាច្រើន ដោយសារសិស្សពុំមានមូលដ្ឋានគ្រឹះក្នុងការអាន

## ៤.៣. ការគ្រប់គ្រងធនធានមនុស្ស

### ៤.៣.១ ចំនួនគ្រូបង្រៀនមុខវិជ្ជាគោល

ក្រាបទី១២៖ ចំនួនគ្រូបង្រៀនមុខវិជ្ជាគោល




តាមរយៈទិន្នន័យក្នុងក្រាហ្វិកខាងលើនេះបានបង្ហាញថាគ្រូបង្រៀនមុខវិជ្ជាគោលនៅសាលាគោលដៅទាំង៤ នៅមិនទាន់គ្រប់គ្រាន់ទេ ។ យោងតាមការលើកឡើងរបស់លោកនាយកសាលាគោលដៅទាំងអស់ គឺមានសាលារៀនចំនួន៣ ដែលលោកនាយកបានបញ្ជាក់ថាពុំមានគ្រូមុខវិជ្ជាគោលគ្រប់គ្រាន់នោះទេ៖វិទ្យាល័យពេជ្រចិន្តា (ខ្វះគ្រូ១០នាក់),វិទ្យាល័យរូងជ្រៃ(ខ្វះ៧នាក់)និង វិទ្យាល័យបវេល(ខ្វះ១៥នាក់) ។

## ៤.៣.២. ការបំប៉ន និងការអភិវឌ្ឍសមត្ថភាពគ្រូ

ក្រាបទី១៣ ៖ ការបំប៉ន និងការអភិវឌ្ឍសមត្ថភាពគ្រូ




ទិន្នន័យខាងលើបានបង្ហាញថា គ្រូបង្រៀនពុំសូវទទួលបានការបំប៉នសមត្ថភាពនៅនឹងកន្លែងនោះទេ គ្រូបង្រៀនដែលទទួលបានការបំប៉នម្តងម្កាលមានចំនួន ៧៦% ហើយគ្រូបង្រៀនចំនួន ២៤% ទៀតពុំធ្លាប់ទទួលបានការបំប៉នសមត្ថភាពអ្វីឡើយ។ យោងតាមប្រសាសន៍លោកនាយកសាលាទាំងអស់ គឺនៅពេលចាប់ផ្តើមគម្រោងមានគ្រូបង្គោលថ្នាក់ជាតិ ចុះមកណែនាំផ្នែកបច្ចេកទេស និងផ្តល់ឯកសារជំនួយមួយចំនួនពីរបៀបធ្វើតេស្តស្តង់ដា។ប៉ុន្តែលោកនាយកសង្កេតឃើញថា លោកគ្រូ/អ្នកគ្រូ ហាក់ដូចជាមិនសូវយល់ច្បាស់ពីរបៀបរៀបចំតេស្តទៅតាមកម្រិតនៅឡើយ។ ចំណែកឯការអភិវឌ្ឍសមត្ថភាពវិញ លោកនាយកសាលាទាំងអស់បានបញ្ជាក់ថា ក្រសួងមានផ្តល់អាហារូបករណ៍ដល់គ្រូបង្រៀនដែលចង់ទៅបន្តការសិក្សាបរិញ្ញាបត្រនៅថ្ងៃសៅរ៍ អាទិត្យ(នៅសកលវិទ្យាល័យភូមិន្ទ )។ប៉ុន្តែជាក់ស្តែងមានគ្រូមួយចំនួនតូចប៉ុណ្ណោះដែលបានសម្រេចចិត្តទៅរៀនបន្ដដោយសារពួកគាត់ថាឆ្ងាយពិបាកក្នុងការធ្វើដំណើរ។

### ៤.៣.៣. ការចុះអធិការកិច្ច

ក្រាបទី១៩៖ការចុះអធិការកិច្ច




តាមរយៈទិន្នន័យក្រាហ្វិកខាងលើ បង្ហាញថាលោកនាយកភាគច្រើនមានការចុះអធិការកិច្ចរាល់ត្រីមាស ដោយមានគ្រូបង្រៀនចំនួន ៦៤% បានលើកឡើងពីការចុះអធិការកិច្ចប្រចាំត្រីមាស។ទិន្នន័យដែលទទួលបានពីលោកនាយកសាលាគោលដៅទាំងអស់បានឱ្យដឹងថាការធ្វើអធិការកិច្ចនេះគឺលោកនាយក នាយករង ឬ ប្រធានក្រុមបច្ចេកទេស រៀបចំធ្វើផែនការចុះអធិការកិច្ច ដោយបានបិទផ្សាយ ១សប្តាហ៍ មុនពេលចុះធ្វើកិច្ចការនេះ ។ ហើយប្រសិនបើមានការចាំបាច់ លោកនាយកអាចចុះ១ខែម្តងក៏មាន។ នៅក្នុងការគ្រប់គ្រងធនធានមនុស្សមានបញ្ហាប្រឈមខ្លះៗដូចជា៖

- ខ្វះគ្រូមុខវិជ្ជាគោល
- គ្រូនៅឆ្ងាយ សុំផ្ទេរចេញច្រើន (ដោយសារពិបាករកកន្លែងស្នាក់នៅឱ្យពួកគាត់)
- សមត្ថភាពលោកគ្រូ/អ្នកគ្រូនៅមានកម្រិត(មិនទាន់ចេះធ្វើវិញ្ញាសាប្លូម តាម SEIP )
- លោកគ្រូ អ្នកគ្រូមិនទាន់យល់ច្បាស់និងពុំមានលក្ខខ័ណ្ឌត្រឹមត្រូវក្នុងការកំណត់តេស្តស្តង់ដានៅឡើយទេ

## ៤.៤. ការគ្រប់គ្រងហិរញ្ញវត្ថុ

### ៤.៤.១. ការទុកដាក់ និងប្រើប្រាស់ថវិកា

ក្រាបទី១៥៖ ការទុកដាក់ និងប្រើប្រាស់ថវិកា




យោងតាមទិន្នន័យក្រាហ្វិកខាងលើនេះបង្ហាញថា លោកនាយកពិតជាមានគណនេយ្យភាព និងតម្លាភាពក្នុងការរក្សាទុកថវិកា និងការប្រើប្រាស់ថវិកាដោយមានគ្រូបង្រៀនចំនួន ៦០% បានបញ្ជាក់ថាបានប្រជុំពិភាក្សាញឹកញាប់ជាមួយ គណៈគ្រប់គ្រង និងអ្នកពាក់ព័ន្ធផ្សេងទៀត រីឯគ្រូបង្រៀន ៤០% ទៀតបានចូលរួមប្រជុំម្តងម្កាល។បើយោងតាមប្រសាសន៍របស់លោកនាយកសាលាគោលដៅទាំងអស់បានឱ្យដឹងថា ថវិកាសាលារៀនត្រូវបានរក្សាទុកមានសុវត្ថិភាពគឺសាលារៀននីមួយៗមានគណនេយ្យនៅធនាគារ អេស៊ីលីដា និងមានគណៈកម្មការប្រើប្រាស់ថវិកា (៥នាក់ )។ គណៈគ្រប់គ្រងសាលារៀនមានការប្រជុំពិភាក្សាជាមួយអ្នកពាក់ព័ន្ធដូចជា៖ គណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស), ប្រធានក្រុមបច្ចេកទេស ,គ្រូគ្រប់មុខវិជ្ជា

(ពេលខ្លះប្រជុំទាំងអស់ ពេលខ្លះប្រជុំតាមមុខវិជ្ជា រួចប្រធានក្រុមស្រង់គំនិតដើម្បីលើកឡើងពេលប្រជុំរួម ) និងអាណាព្យាបាលសិស្ស ដើម្បីរៀបចំគ្រោងថវិកា និងការចំណាយប្រចាំឆ្នាំនៅដើមឆ្នាំសិក្សា។ហើយការគ្រោងថវិកានេះគឺផ្តោតសំខាន់ទៅលើការបង្រៀននិងរៀន។ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុក៏មានបញ្ហាលំបាកមួយចំនួនដូចខាងក្រោម៖

- សាលាពុំមានថវិកាសម្រាប់ឧបត្ថមគ្រូដើម្បីបំប៉នសិស្សរៀនយឺតទេ។
- ការប៉ាន់តម្លៃសម្ភារៈអាចមានភាពខ្វះចន្លោះ
- បុគ្គលិកខ្លះគាត់មានភាពយឺតយ៉ាវក្នុងការទូទាត់ការចំណាយជាមួយគណនេយ្យ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និង

# សំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១- សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ អង្កេត និងសម្ភាសលោកនាយកសាលាបន្ថែមនៅតាមសាលាគោលដៅទាំង៤ ទៅលើប្រធានបទ “ **ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តបាត់ដំបង** ” អ្នកសិក្សាស្រាវជ្រាវ បានប្រមូលព័ត៌មាននិងធ្វើការសន្និដ្ឋានថា៖ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅសាលាគោលដៅទាំង៤នៅក្នុងខេត្តបាត់ដំបង មានកម្រិតល្អបង្គួរ និងមានចំណុចខ្វះខាតមួយចំនួន។

លទ្ធផលស្រាវជ្រាវបានបង្ហាញថា៖លោកនាយកសាលាគោលដៅទាំង៤ មានចំណុចជាច្រើនដែលត្រូវតាមស្តង់ដារបស់នាយកសាលា ដែលជាកត្តាដ៏សំខាន់មួយដែលនាំឱ្យសាលារៀនទទួលជោគជ័យ។ចំណុចទាំងនោះរួមមាន៖ កម្រិតវប្បធម៌និងបទពិសោធន៍ការងាររបស់លោកនាយក, តម្លាភាពក្នុងការគ្រប់គ្រង(១០០%), ការកៀគរថវិកាសម្រាប់អភិវឌ្ឍសាលា(៩៦%), ការវាយតម្លៃគ្រូ សិស្ស សាលារៀនបានល្អ(៩៤%), ការលើកទឹកចិត្ត និងដាក់ពិន័យរដ្ឋបាល, ការចុះអធិការកិច្ចប្រចាំត្រីមាស(៦៤%) និងការរក្សាទុកថវិកានិងផែនការចំណូលចំណាយមានការប្រជុំជាមួយអ្នកពាក់ព័ន្ធ (៦០%) ។ ចំណែកគ្រូក៏រៀបចំកិច្ចតែងការបានល្អ(៨៨%),ប្រជុំបច្ចេកទេសបានទៀងទាត់(៩០%), ដាក់កិច្ចការផ្ទះបានល្អ(៨៤%), គ្រូជួបពិភាក្សាជាមួយមាតាបិតាសិស្សរៀនយឺត(៧៨%)។

ទន្ទឹមនឹងនោះការអនុវត្តការគ្រប់គ្រងតាមសាលារៀនក៏ជួបនូវបញ្ហាមួយចំនួនដូចជា៖

១.)លទ្ធផលសិក្សារបស់សិស្សមួយចំនួននៅខ្សោយដែលនាំឱ្យអត្រាសិស្សបោះបង់ការសិក្សាខ្ពស់, ២.) ខ្វះគ្រូមុខវិជ្ជាគោល, ៣.) សមត្ថភាពធនធាននៅមានកម្រិត៖ គ្រូបង្រៀនមួយចំនួនពុំទាន់យល់ច្បាស់ពីរបៀបបង្កើតតេស្តស្តង់ដាទៅតាមកម្រិតថ្នាក់នីមួយៗរបស់ខ្លួម រីឯចំណេះដឹងផ្នែកពិសោធន៍ និងកុំព្យូទ័រវិញក៏នៅខ្វះខាតដែរ , ៤.)ខ្វះបន្ទប់សិក្សានិងសម្ភារៈសិក្សា , ៥.)ចំណែកការបំប៉នសិស្សរៀនយឺតមិនសូវបានម៉ត់ចត់ទេ(កត្តាសិស្សខ្លួនឯងផង,កត្តាអាណាព្យាបាលសិស្សមួយចំនួនមិនសូវចូលរួមផង ហើយសាលាក៏ពុំមានថវិកាគ្រប់គ្រាន់សម្រាប់ឧបត្ថម្ភគ្រូគ្រប់មុខវិជ្ជាដើម្បីបំប៉នសិស្សរៀនយឺត) ។

យោងតាមការស្រាវជ្រាវរបស់Joyce,John&Joash (២០១៣) និងការស្រាវជ្រាវពីការគ្រប់គ្រងរបស់សាលាជោគជ័យនានា ,បញ្ហាទាំងនេះជាបញ្ហាសំខាន់ដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តការងារនេះ ។

## ៥.២- សំណូមពរ

តាមរយៈលទ្ធផលនៃការស្រាវជ្រាវនេះ អ្នកសិក្សាបានរកឃើញថាមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលរាំងស្ទះដល់ប្រសិទ្ធភាពនៃការអនុវត្តការងារគ្រប់គ្រងតាមសាលារៀនគោលដៅទាំង៩នោះ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហា និងតម្រូវការទាំងនោះ អ្នកស្រាវជ្រាវសូមលើកឡើងនូវគំនិតយោបល់ មួយចំនួនសម្រាប់ភាគីពាក់ព័ន្ធដើម្បីចូលរួមចំណែកធ្វើឱ្យការគ្រប់គ្រងតាមសាលារៀនកាន់តែមានប្រសិទ្ធភាពខ្ពស់សំដៅជំរុញដល់លទ្ធផលសិក្សារបស់សិស្សឱ្យកាន់តែប្រសើរឡើង ៖

- **ក្រសួងអប់រំ យុវជន និងកីឡា**
  - ស្នើសុំក្រសួងអប់រំ យុវជន និងកីឡាបន្តបើកវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពដល់លោកគ្រូ/អ្នកគ្រូដូចជា ៖ វគ្គបំប៉នបច្ចេកទេសលើបន្ទប់មុខវិជ្ជា (រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ) និង ផ្នែកកុំព្យូទ័រ, វគ្គបំប៉នអំពីរបៀបបង្កើតតេស្តស្តង់ដា(ប្លូម) ។
  - ស្នើឱ្យក្រសួងអប់រំសហការជាមួយមន្ទីរអប់រំដើម្បីប្រជុំផ្សព្វផ្សាយនិងណែនាំពីសារសំខាន់ឱ្យបានច្បាស់លាស់អំពីគម្រោងពង្រឹងការអប់រំមធ្យមសិក្សា(SEIP)ទៅដល់លោកគ្រូ/អ្នកគ្រូ សហគមន៍ និងអាណាព្យាបាលសិស្ស ដើម្បីជំរុញការចូលរួមបន្ថែមទៀត។
- **មន្ទីរអប់រំ យុវជន និងកីឡាខេត្ត**
  - សូមឱ្យមន្ទីអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង សហការជាមួយក្រសួងអប់រំក្នុងការចែងគោលការណ៍ផ្តល់គ្រូឱ្យបានច្បាស់លាស់តាមតម្រូវការជាក់ស្តែង និងឱ្យត្រូវតាមឯកទេសផង។

- **គណៈគ្រប់គ្រងសាលា**

  សូមឱ្យគណៈគ្រប់គ្រងសាលារៀនពង្រឹងទំនាក់ទំនងល្អជាមួយៈ មន្រ្តីអប់រំគ្រប់លំដាប់ថ្នាក់ អាជ្ញាធរដែនដី សម្បុរសជន សហគមន៍ អាណាព្យាបាលសិស្សនិងសិស្សានុសិស្ស ដើម្បីកៀគរថវិកាសម្រាប់អភិវឌ្ឍសាលារៀន។

- **ចំពោះអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ**

  សូមឱ្យអ្នកសិក្សាក្រោយៗ ធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀតទៅលើប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល នៅតាមសាលាគោលដៅទាំង៤នេះ ដើម្បីសិក្សាឱ្យកាន់តែច្បាស់អំពីចំណុចខ្វះខាត ហើយនិងផ្តល់នូវអនុសាសន៍ល្អៗ បន្ថែមទៀត សំដៅជំរុញគុណភាពនៃការអប់រំយើងឱ្យកាន់តែប្រសើរឡើង។

# ឯកសារយោង

# ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា(២០១៧),សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន (សម្រាប់បឋមសិក្សា)។

ក្រសួងអប់រំ យុវជន និងកីឡា: សៀវភៅតួនាទី និងការទទួលខុសត្រូវរបស់នាយក នាយករង និងលេខាធិការ ថ្ងៃទី០១ ខែ មករា ឆ្នាំ២០១១។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧),ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល:ឯកសារប្រតិបត្តិ គោលនយោបាយ និងនីតិវិធីគ្រប់គ្រងសាលារៀនសម្រាប់បឋមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧),ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល:ឯកសារប្រតិបត្តិ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនសម្រាប់បឋមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៧),ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល:ឯកសារប្រតិបត្តិ ការងារអធិការកិច្ចសាលារៀនផ្តោតលើបច្ចេកទេសរៀន និងបង្រៀន សម្រាប់បឋមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧),ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល:ឯកសារប្រតិបត្តិ ការគ្រប់គ្រងថវិកាសាលារៀនសម្រាប់បឋមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧),ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល:ឯកសារប្រតិបត្តិការស្វ័យវាយតម្លៃសាលារៀនសម្រាប់បឋមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧), ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល:ការគ្រប់គ្រងរដ្ឋបាលសាលារៀនសម្រាប់បឋមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨),បទបង្ហាញស្តីពីគុណភាពគ្រូជាគុណភាពមូលធនមនុស្សសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨), សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន (គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា)។

Asian Development Bank (2002). *Technical Assistance to the Kingdom of Cambodia for performance management in the education sector*. Phnom Penh: Cambodia, Asian Development Bank

Benjamin, Y.M.C., & Sheung, C.H. (1997). Parent participation in school councils in Victoria, Australia. *The International Journal of Educational Management*, 11(3), 102-112

Blom, H.C.J., & Nooijer, P.G.de. (1992). *Focus on higher education and vocational training in Cambodia: Report on a NUFFIC fact finding mission*: The Hague: Netherlands, Nuffic: Netherlands Organisation for International Cooperation in Higher Education.

Caldwell, B.J. (2005). *School-based management*. UNESCO, Education Policy Booklet Series (3), jointly published by The International Institute for Educational Planning, Paris, France, and The International Academy of Education, Brussels, Belgium

Canston, N.C. (2001). Collaborative decision-making and school-based management: Challenges, rhetoric and reality. *Journal of Educational Enquiry*, 2(2), 1-24.

Dykstra, A.H., & Kucita, P. (1997). *SBM through cluster schools: A case study from Cambodia*. Retrieved May 8, 2006, from http://www1.worldbank.org/education/est/resources/case%20studies/Cambodia%20-%20UNICEF.doc

John,Samir,Anton,K.Sujatha,Ashok,Krishna,Hridya,...Wilfred.(2011).*Successful Schools.*

Ministry of Education, Youth and Sport (2000). *Education strategic plan 2001-2005*. Phnom Penh: Cambodia, Ministry of Education, Youth and Sport.

Ministry of Education, Youth and Sport (2001a). *Education strategic plan: Broad policy priorities, 2001-2005*. Phnom Penh: Cambodia, Ministry of Education, Youth and Sport.

Ministry of Education, Youth and Sport (2001b). *Priority action program for improving the quality and effectiveness of basic education 2001*. Phnom Penh: Cambodia, Ministry of Education, Youth and Sport.

Ministry of Education, Youth and Sport (2005). *Education strategic plan 2006-2010.* Phnom Penh: Cambodia, Ministry of Education, Youth and Sport.

Pellini, A. (2005). Decentralization of education in Cambodia: Searching for space of participation between traditions and modernity. *Compare* (Journal), 36(2), 205-216.

Rogers, D., & Chung, N.H. (1983). *110 Livingston Street revisited: Decentralisation in action*. New York: New York University Press.

Shoraku , A 2005.*"School-parent partnership in school level-management*: A case study of Primary schools in Cambodia"[Asian Educational Study monograraphs 5]:15-29

Shoraku , A 2007."Local response to scholl-based management reform in Cambodia in Asisn context"

Shoraku , A 2008a."Parental participation in Education in Cambodia:Discourses of participation in local context"[Asian Educational Study monograraphs 8]:36-50

Shoraku , A 2008b."A case study of Parental participation in Primary School education in Kampong Chhang Province,Cambodia"[Comparative Education 36]:3-24

Walker, E.M. (2002). The politics of school-based management: Understanding the process of devolving authority in urban school districts. *Education Policy Analysis Archives*, 10(33), 1-22.

Wong, E.O.W. (2003). Leadership style for SBM in Hong Kong. *The International Journal of Educational Management*, 17(6/7), 243-247.

World Bank ( 2007 ).*What is School- Based Management?*Washington, D.C.:World Bank.

World Bank ( 2017 ).Cambodia-Secondary Education Improvement Project (English)Washington, D.C .:World Bank Group

**ព្រះរាជាណាចក្រកម្ពុជា**

**ក្រសួងអប់រំ យុវជន និងកីឡា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់គ្រូបង្រៀន

នាងខ្ញុំឈ្មោះ **ខួន ផល្លី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ដែលកំពុងសរសេរនិក្ខេបបទបញ្ចប់ការសិក្សាក្រោមប្រធានបទ ″ **ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅសាលាមធ្យមសិក្សាបឋមភូមិ** ″ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការរបស់លោក-លោកស្រីដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបំពេញកម្រងសំណួរនេះ។នាងខ្ញុំសូមធានាថា កម្រងសំណួរនេះនឹងត្រូវរក្សាការសម្ងាត់ ហើយព័ត៌មានដែលទទួលបានត្រូវបានយកមកប្រើសម្រាប់ការស្រាវជ្រាវនេះតែប៉ុណ្ណោះ។

**ព័ត៌មានទូទៅ**

ឈ្មោះសាលារៀន ........................................ បង្រៀនថ្នាក់ទី ........................................

មុខវិជ្ជាឯកទេស ........................................ មុខវិជ្ជាបង្រៀន ........................................

កម្រិតវិជ្ជាជីវៈ ........................................ កម្រិតវប្បធម៌ ......................................

**ផ្នែកទី១ ៖ ការគ្រប់គ្រងរដ្ឋបាល**

១-តើសាលារៀនរបស់លោក/លោកស្រីបានបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដែរឬទេ?

☐ មិនមាន ☐ មាន

២-តើលោក/លោកស្រីធ្លាប់បានចូលរួមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន,ផែនការប្រតិបត្តិប្រចាំឆ្នាំឬផែនការផ្សេងៗជាមួយគណៈគ្រប់គ្រងសាលា មាតាបិតាសិស្ស និងសហគមន៍ដែរឬទេ?

☐ មិនធ្លាប់ ☐ ធ្លាប់

បើធ្លាប់តើលោកលោកស្រីរៀបចំផែនការទាំងនោះផ្អែកលើអ្វីខ្លះ?

……………………………………………………………………………………………………

……………………………………………………………………………………………………

៣-តើលោកនាយក/លោកស្រីនាយិកាធ្លាប់បានរៀបចំសម្របសម្រួលសកម្មភាពប្រមូលមូលនិធិសម្រាប់អភិវឌ្ឍសាលារៀនដែរឬទេ?

☐ មិនធ្លាប់ ☐ ធ្លាប់

៤-តើលោកនាយក/លោកស្រីនាយិកាធ្លាប់បានប្រមូលព័ត៌មានជាក់ស្តែងពីការវាយតម្លៃលទ្ធផលសិក្សាសិស្ស ការវាយតម្លៃសមត្ថភាពគ្រូ និងការវាយតម្លៃការអនុវត្តរបស់សាលារៀនដែរឬទេ?

☐ មិនធ្លាប់ ☐ ធ្លាប់

៥-តើលោកនាយក/លោកស្រីនាយិកាធ្លាប់បានប្រជុំពិភាក្សាជាមួយលោក/លោកស្រី និងអ្នកពាក់ព័ន្ធ សំខាន់ៗដើម្បីកំណត់បញ្ហាប្រឈមដែរឬទេ?

☐ មិនធ្លាប់ ☐ ធ្លាប់

៦-តើលោកនាយក/លោកស្រីនាយិកាធ្លាប់បានផ្តល់ការលើកទឹកចិត្តតាមរយៈប័ណ្ណសរសើរឬការផ្តល់រង្វាន់ដល់បុគ្គលិកដែលបំពេញការងារល្អដែរឬទេ?

☐ មិនធ្លាប់ ☐ ធ្លាប់ (សូមបញ្ជាក់……………………………………… ……………)

៧-តើលោកនាយក/លោកស្រីនាយិកាធ្លាប់បានចេញវិធានការរដ្ឋបាល សម្រាប់បុគ្គលិកដែលអសកម្មដែរឬទេ?

☐ មិនធ្លាប់ ☐ ធ្លាប់ (សូមបញ្ជាក់……………………………………… ……………)

៨-តើលោកនាយក/លោកស្រីនាយិកាធ្លាប់បានផ្សព្វផ្សាយទិន្នន័យ(ចំណូល ចំណាយ ថវិកាមានស្រាប់) និងព័ត៌មានផ្សេងៗរបស់សាលារៀនដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋានដែរឬទេ?

☐ មិនធ្លាប់ ☐ ធ្លាប់

## ផ្នែកទី២៖ ការគ្រប់គ្រងការរៀន និងបង្រៀន

៩-តើលោក/លោកស្រីបានរៀបចំរដ្ឋបាលថ្នាក់ និងកិច្ចតែងការបង្រៀនតាមផែនការឬទេ?

☐ មិនបាន ☐ បានតិចតួច ☐ បានល្អបង្គួរ ☐ បានល្អ

១០-តើលោក/លោកស្រីបានដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើដែរឬទេ?

☐ មិនធ្លាប់ ☐ម្តងម្កាល ☐ ញឹកញាប់ ☐ ជាប្រចាំ

១១-តើមុខវិជ្ជាលោក/លោកស្រីមានការប្រជុំបច្ចេកទេសប្រចាំខែទៀងទាត់ដែរឬទេ ?

☐ មិនមាន ☐ មាន

បើមានតើការប្រជុំនោះផ្តោតលើអ្វីខ្លះ……………………………………………………………. ……..

……………………………………………………………………………………………………………….

បើគ្មានមូលហេតុអ្វី?……………………………………………………………………………….

១២-តើលោក /លោកស្រី ធ្លាប់បានប្រជុំ ប្រឹក្សាយោបល់ជាមួយមាតាបិតាសិស្ស និងសិស្សរៀនយឺតដែរឬទេ?បើប្រជុំតើញឹកញាប់ប៉ុនណា?

☐ មិនធ្លាប់ ☐ ធ្លាប់ (សូមបញ្ជាក់……………………………………………….)

១៣-តើសាលារៀនលោក/លោកស្រីមានបន្ទប់រៀនគ្រប់គ្រាន់សម្រាប់សិស្សតាមបទដ្ឋានដែរឬទេ ?

☐ គ្រប់គ្រាន់ ☐ មិនគ្រប់គ្រាន់

១៤-តើលោក /លោកស្រីបានបង្កើតតេស្តស្តង់ដាដើម្បីវាយតម្លៃលទ្ធផលសិក្សាសិស្សដែរឬទេ? តើការវាយតម្លៃនេះមានប៉ុន្មានដំណាក់កាល? (សូមបញ្ជាក់)

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

១៥-តើសាលារៀនរបស់លោក/លោកស្រីមានកម្មវិធីអ្វីខ្លះដើម្បីជួយសិស្សដែលរៀនយឺត?

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

## ផ្នែកទី៣៖ ការគ្រប់គ្រងធនធានមនុស្ស

១៦-តើសាលារៀនរបស់លោក/លោកស្រីមានគ្រូបង្រៀនមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម)គ្រប់គ្រាន់ដែរឬទេ ?

☐ មិនគ្រប់គ្រាន់ ☐ ខ្វះតិចតួច ☐ ខ្វះមធ្យម ☐ ខ្វះច្រើន ☐ លើស

១៧-តើលោក /លោកស្រី ធ្លាប់ទទួលការបំប៉ន និងការអភិវឌ្ឍសមត្ថភាពផ្សេងៗដែរឬទេ ?

☐ មិនធ្លាប់ ☐ម្តងម្កាល ☐ ញឹកញាប់ ☐ ផ្សេងៗ………………

១៨-តើលោកនាយក /លោកស្រីនាយិកាធ្លាប់ចុះធ្វើអធិការកិច្ចលោក /លោកស្រី ដែរឬទេ ?

☐ មិនធ្លាប់ ☐ រាល់ខែ ☐ រាល់ត្រីមាស ☐ ផ្សេងៗ……………..

## ផ្នែកទី៤៖ ការគ្រប់គ្រងហិរញ្ញវត្ថុ

១៩-តើលោកនាយក /លោកស្រីនាយិកា បានប្រជុំពិភាក្សាជាមួយលោកលោក /លោកស្រី និងអ្នកពាក់ព័ន្ធផ្សេងទៀត អំពីការទុកដាក់ថវិកា ផែនការចំណូល ចំណាយរបស់សាលារៀន ដែរឬទេ ?

☐ មិនធ្លាប់ ☐ ម្តងម្កាល ☐ ញឹកញាប់

២០-តើលោក /លោកស្រីជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្តគម្រោងនេះកន្លងមក ?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

សំណូមពរផ្សេងៗ

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់សម្ភាសន៍នាយក/នាយិកា

នាងខ្ញុំឈ្មោះ **ខួន ផល្លី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិជាតិអប់រំ ដែលកំពុងសរសេរនិក្ខេបបទបញ្ចប់ការសិក្សាក្រោមប្រធានបទ"**ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅសាលាមធ្យមសិក្សាបឋមភូមិ**"។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការរបស់លោកនាយក-លោកស្រីនាយិកាដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមក្នុងកិច្ចសម្ភាសន៍នេះ។នាងខ្ញុំសូមធានាថាកម្រងសំណួរនេះនឹងត្រូវរក្សាការសម្ងាត់ ហើយព័ត៌មានដែលទទួលបានត្រូវបានយកមកប្រើសម្រាប់ការស្រាវ ជ្រាវនេះតែប៉ុណ្ណោះ។

**ព័ត៌មានទូទៅ**

ឈ្មោះសាលារៀន ............................................................

បទពិសោធការងារជានាយក/នាយិកា..................................ឆ្នាំ

កម្រិតវិជ្ជាជីវៈ ................................................. កម្រិតវប្បធម៌ ..........................................

**ផ្នែកទី១៖ ការគ្រប់គ្រងរដ្ឋបាល**

១-តើសាលារៀនរបស់លោក/លោកស្រីបានបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀនដែរឬទេ?

.......................................................................................................

.......................................................................................................

.......................................................................................................

២-តើលោកនាយក/លោកស្រីនាយិកាធ្លាប់បានរៀបចំធ្វើផែនការអ្វីខ្លះ?តើការរៀបចំផែនការទាំងនោះមានដំណើរការដូចម្តេចដែរ?

.......................................................................................................

.......................................................................................................

.......................................................................................................

៣-តើមានអ្នកណាខ្លះចូលរួមក្នុងការរៀបចំផែនការទាំងនោះ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៤-តើលោកនាយក/លោកស្រីនាយិកា ធ្វើយ៉ាងដូចម្តេចដើម្បីកៀរគរថវិកាសម្រាប់អភិវឌ្ឍសាលារៀន?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៥-តើលោកនាយក/លោកស្រីនាយិកាមានការវាយតម្លៃលទ្ធផលសិក្សាសិស្ស សមត្ថភាពគ្រូ និងការវាយតម្លៃការអនុវត្តរបស់សាលារៀនដែរឬទេ?តើការវាយតម្លៃទាំងនោះមានដំណើរការយ៉ាងដូចម្តេច?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៦-តើលោកនាយក/លោកស្រីនាយិកាមានការលើកទឹកចិត្តបុគ្គលិកដែលបំពេញការងារល្អ និងមានវិធានការសម្រាប់បុគ្គលិកអសកម្មយ៉ាងដូចម្តេច?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៧-តើលោកនាយក/លោកស្រីនាយិកាបានផ្សព្វផ្សាយទិន្នន័យ(ចំណូល ចំណាយ ថវិកាមានស្រាប់) និងព័ត៌មានផ្សេងៗរបស់សាលារៀនដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋានដែរឬទេ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៨-តើលោកនាយក/លោកស្រីនាយិកាជួបប្រទះបញ្ហារាំងស្ទះអ្វីខ្លះក្នុងការគ្រប់គ្រងរដ្ឋបាលកន្លងមក?

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

## ផ្នែកទី២៖ ការគ្រប់គ្រងការរៀន និងបង្រៀន

៩-តើលោកគ្រូ/អ្នកគ្រូបានបំពេញរដ្ឋបាលថ្នាក់ និងរៀបចំកិច្ចតែងការបង្រៀនតាមផែនការទេ?

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

១០-តើមុខវិជ្ជាលោក/លោកស្រីមានការប្រជុំបច្ចេកទេសប្រចាំខែទៀងទាត់ដែរឬទេ ?

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

១១-តើលោកគ្រូ/អ្នកគ្រូបានដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើញឹកញាប់ប៉ុនណា?

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

១២-តើលោកគ្រូ/អ្នកគ្រូបានប្រជុំប្រឹក្សាយោបល់ជាមួយមាតាបិតាសិស្ស និងសិស្សរៀនយឺតញឹកញាប់ប៉ុនណា?

……………………………………………………………………………………………….

……………………………………………………………………………………………….

……………………………………………………………………………………………….

១៣-តើលោកនាយក/លោកស្រីនាយិកាមានកម្មវិធីអ្វីខ្លះដើម្បីជួយដល់សិស្សដែលរៀនយឺត?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

## ផ្នែកទី៣៖ ការគ្រប់គ្រងធនធានមនុស្ស

១៤-តើសាលារៀនរបស់លោកនាយក/លោកស្រីនាយិកាមានគ្រូបង្រៀនមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម)គ្រប់គ្រាន់ដែរឬទេ ?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

១៥-តើលោកនាយក/លោកស្រីនាយិកាមានកម្មវិធីបំប៉ន និងការអភិវឌ្ឍសមត្ថភាពផ្សេងៗដល់បុគ្គលិកដែរឬទេ?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

១៦-តើលោកនាយក /លោកស្រីនាយិកាបានចុះធ្វើអធិកាកិច្ចលោកគ្រូ/អ្នកគ្រូញឹកញាប់ប៉ុនណា ?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

**ផ្នែកទី៤៖ ការគ្រប់គ្រងហិរញ្ញវត្ថុ**

១៧-តើលោកនាយក /លោកស្រីនាយិកា ធ្វើដូចម្តេចដើម្បីឱ្យការប្រើប្រាស់ថវិកាប្រកបដោយគណនេយ្យភាព និងតម្លាភាព?

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

១៨-តើលោកនាយក/លោកស្រីនាយិកាមានបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្ត"**ការគ្រប់គ្រងតាមសាលារៀន**" ទាំងលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់ការរៀននិងបង្រៀន ការគ្រប់គ្រងបុគ្គលិក និងការគ្រប់គ្រងហិរញ្ញវត្ថុ?

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

១៩-តើលោកនាយក/លោកស្រីនាយិកាមានសំណូមពរអ្វីខ្លះដល់ដឹកនាំ មន្ទីរ ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីគាំទ្រដល់ការងារគ្រប់គ្រងសាលារៀននេះឱ្យកាន់តែមានប្រសិទ្ធភាព?

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

………………………………………………………………………………………………….

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៦២៩ **អយក.** ១៧

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម **យក់ ឌ៉ុយ** | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម **ណាង សេងហាក់** | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម **ម៉ក់ ងយ** | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកដឹកនាំវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៩៦២៩ អយក. [illegible]

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈុក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៩៧៣១ **អយក.** ១៧
(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖**-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការកណ្តាល** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-លោកស្រី ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-លោក ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោក សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវមកបំពេញភារកិច្ចនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃបន្តបន្ទាប់ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh